ព្រឹត្តិបត្រ មរតកខ្មែរ
Morodok Khmer

លេខ ០២ ឆ្នាំទី ០១ ខែមេសា គ.ស. ២០១០ - ព.ស. ២៥៥៣

# ពិធីបុណ្យចូលឆ្នាំខ្មែរ វត្តខេមររង្សី ក្រុងសាន់ហ្វូសេ




## អំពីប្រវត្តិបុណ្យចូលឆ្នាំខ្មែរ ប្រពៃណីជាតិ

មាតិការឿង ទំព័រ


- ជីវិតនិងសង្គម................................០៤
- ត្រូវចេះប្រើប្រាក់ កុំឱ្យ....................០៧
- រក្សាកាយ វាចា ចិត្ត ជីវិត.................០៩
- ប្រវត្តិសង្ខេប នៃការកសាងវត្ត..........១២
- ជំនឿរបស់ខ្មែរមុនការទទួល...........១៣
- ជីវប្រវត្តិសង្ខេបនិងការតស៊ូ.............១៧
- ខ្មែរក្រោមម្នាក់ត្រូវកាត់ទោស...........១៩
- រដ្ឋាភិបាលខ្មែរមិនពេញចិត្ត..............២០
- ខួបទី៤០នៃរដ្ឋប្រហារ.......................២១
- សភាបានអនុម័តច្បាប់.....................២៣
- ប្រសិទ្ធិពរឆ្នាំថ្មី...................................៣០


មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ នៅលើពិភពលោកយើងនេះ តែងតែប្រារព្ធបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិរៀងៗខ្លួន គ្រាន់តែមានការកំណត់ពេលវេលាខុសប្លែកពីគ្នាទៅតាមទំនៀមទម្លាប់និងជំនឿរបស់ខ្លួនតែប៉ុណ្ណោះ។ ដោយឡែកប្រជាពលរដ្ឋខ្មែរយើងវិញ នៅតែរក្សាការពារទំនៀមទម្លាប់នេះ តាំងពីបុរាណកាលមកម្ល៉េះ។

ប្រជាជនខ្មែរយើង កាលពីមុនសម័យក្រុងនគរធំ ខ្មែរនិយមប្រើចន្ទគតិ( ដំណើរនៃព្រះចន្ទ )គឺកំណត់បុណ្យចូលឆ្នាំថ្មីនៅខែមិគសិរ។ លុះក្រោយមកខ្មែរយើងបានប្តូរមកប្រើសុរិយគតិ( ដំណើរនៃព្រះអាទិត្យ )ទើបកំណត់បុណ្យចូលឆ្នាំថ្មីនៅខែចេត្រវិញតាមព្រះអាទិត្យចរចូលកាន់មេសារាសី ក្នុងរដូវក្តៅជារៀងរាល់ឆ្នាំ ជាប់រហូតមកដល់សព្វថ្ងៃនេះ។ ថ្ងៃចូលឆ្នាំខ្មែរច្រើនតែចំលើថ្ងៃ១៣មេសា ប៉ុន្តែជួនកាលយូរៗម្តង(**តទៅទំព័រទី៨**)

# វត្តខេមររង្សី ក្រុងសាន់ហូសេ

**1594 Cunningham Ave San Jose, CA 95122**
**Tel: (408) 923-2166 / 550-5060**
**http://www.unitedkhmerkrom.org**


## *លិខិតអញ្ជើញបុណ្យចូលឆ្នាំខ្មែរ*

ដើម្បីអបអរសាទរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ **ឆ្នាំខាល** ទោស័ក ព.ស ២៥៥៤ និងរក្សានូវទំនៀមទម្លាប់ វប្បធម៌ ព្រមទាំងទទួលទេពធីតាឆ្នាំថ្មី នាម **មណ្ឌាទេវី** ជាបុត្រីទី៤នៃកបិលមហាព្រហ្ម និងការនាំមកនូវសិរីសួស្តី ជ័យមង្គលគ្រប់ប្រការ ឱ្យកើតមានដល់ក្រុមគ្រួសារខ្មែរយើងគ្រប់ៗគ្នានោះ យើងខ្ញុំព្រះករុណា អាត្មាភាព ជាគណៈកម្មការពុទ្ធិកសមាគមខ្មែរក្រោម **វត្តខេមររង្សី** ទីក្រុងសាន់ហូសេ បានមូលមតិគ្នារៀបចំពិធីបុណ្យ ដែលមានកាលបរិច្ឆេទដូចខាងក្រោម ៖

**កម្មវិធីបុណ្យ នៃវត្តខេមររង្សី**

- ថ្ងៃពុធ ទី ១៤ ខែ មេសា ឆ្នាំ២០១០ ( Wednesday April. 14, 2010)
- ថ្ងៃព្រហស្បតិ៍ ទី ១៥ ខែ មេសា ឆ្នាំ២០១០ ( Thursday  April. 15, 2010)
- ថ្ងៃសុក្រ ទី ១៦ ខែ មេសា ឆ្នាំ២០១០ ( Friday April. 16, 2010)

- *បញ្ចាក់៖ ថ្ងៃសៅរ៍ ទី ១៧ ខែមេសា ឆ្នាំ២០១០ (Saturday April.17, 2010 )*

ចាប់ពីម៉ោង 8:30AM—10:00PM ពិធីពុទ្ធសាសនា, របាំប្រពៃណី, ល្បែងប្រជាប្រិយ៍ និងដូរ្យតន្ត្រីសម័យ **មិត្តភាពតន្ត្រី** កំដរច្រៀងរាំកំសាន្តជូនបងប្អូនញាតិមិត្តជិតឆ្ងាយ នៅសាលារៀនមុខវត្ត **Slonaker Elementary School 1601 Cunningham Ave, San Jose, CA 95122.**

- *ថ្ងៃអាទិត្យ ទី ១៨ ខែ មេសា ឆ្នាំ២០១០ ( Sunday April. 18, 2010)*

ពីម៉ោង 8:30AM–3:00PM ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ ធ្វើពិធីនមស្សការ, សមាទានសីល, រាប់បាត្រ, វេរភត្ត, ដារបង្សុកូល, ពូនភ្នំខ្សាច់ និងស្រង់ព្រះ ជាកិច្ចឆ្លងបុណ្យ នៅក្នុងវត្តខេមររង្សី។

អាស្រ័យហេតុនេះ សូមគោរពអញ្ជើញ ពុទ្ធបរិស័ទ និងលោក លោកស្រី មេត្តាចូលរួមអនុមោទនានូវបុណ្យកុសល និងរីករាយសប្បាយក្នុងពិធីបុណ្យចូលឆ្នាំថ្មី ជាមួយយើងខ្ញុំដោយមេត្រីភាព។

*-សូមជំរាបជូនថា ថ្ងៃទី ១៤-១៥-១៦-១៨ ខែមេសា ប្រារព្ធពិធីបុណ្យនៅក្នុងវត្តខេមររង្សី។*

**Invitation**

On behalf the **Watt Khemara Rangsey** members in San Jose, we would like to invite you and your family to attend and celebrate our **Cambodian New Year on Wednesday, Thursday, Friday, Saturday and Sunday April 14-15-16-17-18, 2010 from 8:30AM – 10:00PM at 1594 Cunningham Ave. San Jose, CA 95122.** Your present at our New Year celebration is an honor for our community. We are looking forward to meet you at our New Year celebration.

***ព័ត៌មានបន្ថែម៖ Tel: (408) 923-2166 / 550-5060/ 314-6929/ 531-5730/ 887-9374***

# មូលហេតុ
## ស្តីពីការចេញផ្សាយ នៃព្រឹត្តិប័ត្រ មត៌កខ្មែរ

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** នៃពុទ្ធិកសមាគមខ្មែរក្រោម វត្តខេមររង្សី នៅទីក្រុងសាន់ហូស្សេ នឹងចេញផ្សាយតាមគេហទំព័រ http://www.unitedkhmerkrom.org / http://morodokkhmer2010.wordpress.com និងបោះពុម្ពផ្សាយជារៀងរាល់ខែ ដើម្បីពង្រឹងពង្រីក វិស័យវប្បធម៌, ប្រពៃណី, ទំនៀមទម្លាប់, ភាសា, អក្សរសាស្ត្រជាតិ និងដំណឹងថ្មីៗ ពីសហគមន៍ខ្មែរ នៅក្នុងនិងក្រៅប្រទេស។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** ផ្សព្វផ្សាយនូវសកម្មភាពសង្គម, ព័ត៌មានខ្មែរ-អន្តរជាតិ, អប់រំ, សុខភាព, កីឡា, រឿងរ៉ាវប្លែកៗ, សីលធម៌, ទស្សនៈកវី និងពុទ្ធសាសនាជាដើម....។ល។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** យកប្រាសាទព្រះវិហារធ្វើជាសញ្ញា (Logo) ដោយប្រាសាទព្រះវិហារ គឺជាទ្រព្យសម្បត្តិរបស់ជាតិខ្មែរ ហើយអង្គការយូនីស្កូ បានចុះក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក កាលពីថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេប៊ិច ប្រទេសកាណាដា។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** ចេញផ្សាយជារៀងរាល់ខែ តាមគេហទំព័រ និងបោះពុម្ពចែកចាយដោយឥតគិតថ្លៃ ចាប់ពីថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១០ នេះតទៅ។

សេចក្តីដូចបានប្រគេន-ជំរាបជូនដំណឹងខាងលើ សូមមិត្តអ្នកអាននៅក្នុងនិងក្រៅប្រទេស ជាពិសេសសហគមន៍ខ្មែរ នៅទីក្រុងសាន់ហូស្សេ មេត្តាជ្រាបជាព័ត៌មាន និងគាំទ្រនូវដំណឹងថ្មីៗ ពីព្រឹត្តិប័ត្រ **មត៌កខ្មែរ** ដោយសោមនស្សរីករាយ។

*បញ្ជាក់៖ លោក លោកស្រី ផ្សាយពាណិជ្ជកម្មជាមួយ ព្រឹត្តិប័ត្រ មត៌កខ្មែរ សូមទំនាក់ទំនង* Tel: **(408) 923-2166**

ធ្វើនៅទីក្រុងសាន់ហូស្សេ, ថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១០

គណៈកម្មការ **ព្រឹត្តិប័ត្រ មត៌កខ្មែរ**

## ព្រឹត្តិប័ត្រមត៌កខ្មែរ

- ព្រះតេគុណ សឹង យ៉ឹង រតនា នាយកការផ្សាយ
- ព្រះតេជគុណ ថាច់ សុរិយា និពន្ធនាយក
- លោក អ៊ុក សុភ័ព្វ សម្រួលអត្ថបទ
- អ្នកស្រី គីលីន វីនីតា ពាណិជ្ជកម្ម
- លោក កោះ ថុន ពិនិត្យអត្ថបទ
- អ្នកស្រី បៃ សុផានី ផ្សព្វផ្សាយ
- លោក នឹង ស៊ិន ទីប្រឹក្សា

## អាសយដ្ឋានទំនាក់ទំនង

**ព្រឹត្តិប័ត្រ មត៌កខ្មែរ**
**MORODOK KHMER**
1594 Cunningham Ave.
San Jose, CA 95122. U.S.A
E-mail: morodokkhmer2010@gmail.com
Tel: (408) 923-2166/890-8877/550-5050
http://www.unitedkhmerkrom.org

# គុណភាពនៃជីវិត

នៅក្នុងសង្គមមនុស្ស ដែលកំពុងរស់នៅលើទ្វីបលោកយើងនេះ តែងតែមានទឹកដី សីលធម៌ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងជំនឿសាសនា របស់ពួកគេរៀងៗខ្លួន ជាពិសេសប្រទេសទាំងនោះ ក៏មានអ្នកដឹកនាំដ៏ឆ្នើមឬអ្នកស្ថាប័នជាតិមួយរូប ប្រកបដោយគតិបណ្ឌិត នៃលទ្ធិប្រជាធិបតេយ្យពេញលេញ។

ពីអតីតកាលរហូតមកទល់បច្ចុប្បន្ន សង្គមខ្មែរតែងផ្សាភ្ជាប់ទៅនិងជំនឿព្រះពុទ្ធសាសនា ដែលជាសាសនាដឹកនាំមនុស្ស ឱ្យឆ្ពោះទៅរកសុខសន្តិភាពក្នុងដួងចិត្ត ហើយជីវិតសង្គមខ្មែរមានការវិវឌ្ឍន៍ទៅតាមនយោបាយនៃមេដឹកនាំទាំងនោះ ប្រជាពលរដ្ឋខ្មែរជាជនជាតិមួយមានលក្ខណៈថ្លៃថ្នូរនិងមានស្មារតីខ្ពស់ក្នុងការចូលរួមសហការជាមួយថ្នាក់ដឹកនាំជាតិ ដើម្បីការពារអត្តសញ្ញាណរបស់ខ្លួនគ្រប់ពេលវេលា។

ក្រោយមកដោយសារតែមេដឹកនាំសង្គមខ្មែរមួយចំនួនខ្វះការពិចារណា និងមានការលោភលន់អំណាចប្រព្រឹត្តអំពើពុករលួយជាពិសេសរហូតដល់ផ្លាស់ប្តូរចិត្តគំនិត ក្បត់ពាក្យសន្យានឹងប្រជារាស្ត្រ លក់ឧត្តមគតិនិងជឿនូវពាក្យឃោសនាប្រទេសជិតខាង ពេលនោះសង្គមខ្មែរក៏ធ្លាក់ចុះដុនដាប នឹងធ្វើឱ្យប្រជាពលរដ្ឋខ្មែរគ្រប់ជាន់ថ្នាក់ រងទុក្ខវេទនា និងជួបប្រទះផលលំបាកយ៉ាងច្រើន ក្នុងការរស់នៅដូចជា ខ្វះទីជំរក ខ្វះស្បៀងអាហារ ខ្វះការទុកចិត្តគ្នា ខ្វះការទំនាក់ទំនងគ្នា ខ្វះសាលារៀន ខ្វះមន្ទីរពេទ្យ កូនព្រាត់ឪពុកម្តាយ ប្រពន្ធព្រាត់ប្តី ប្រទេសជាតិលិចលង់បាត់បង់កេរ្តិ៍ឈ្មោះ ស្រុកកើតសង្គ្រាម គ្មានសន្តិសុខ មនុស្សបាត់បង់សីលធម៌ ធ្វើការលួចប្លន់ឥតត្រាប្រណី មិនមានច្បាប់ទម្លាប់ មន្ត្រីរាជការខ្លះប្រព្រឹត្តអំពើកេងប្រវ័ញ្ច បោកបញ្ឆោតរាស្ត្រទន់ខ្សោយនៅតាមជនបទ ហើយល្បីតែភាពក្រីក្រ អត់ឃ្លាន ល្បែងពាលាជាដើម។ ហេតុនេះហើយទើបធ្វើឱ្យប្រជាពលរដ្ឋខ្មែរអស់សង្ឃឹម ក្នុងបញ្ហាជីវិត និង នយោបាយការពារផលប្រយោជន៍ជាតិ។

ទោះជាយ៉ាងណា ប្រជាពលរដ្ឋខ្មែរ នៅតែខិតខំ តស៊ូ ប្តូរជីវិត ជាមួយនឹងការងារសុចរិតនៅស្រុកគេនិងតាំងទីលំនៅថ្មី ដោយសារតែស្រុកកើតសង្គ្រាម... ហើយប្រជាពលរដ្ឋទាំងនោះ នៅតែមានទឹកចិត្តគោរពស្រឡាញ់សង្គមនិងរក្សាការពារ ប្រពៃណី វប្បធម៌ជាតិព្រះពុទ្ធសាសនាជានិច្ចពីព្រោះអត្តសញ្ញាណជាតិរបស់ខ្លួនមានអត្ថប្រយោជន៍ខ្លាំងណាស់ ហើយក៏ជាដួងព្រលឹងនៃសង្គមមនុស្សគ្រប់មូលដ្ឋាន មិនថាតែជនជាតិខ្មែរទេ ជនជាតិណាក៏ដោយ ក៏មានភារកិច្ចការពារអត្តសញ្ញាណជាតិនិងសង្គមដូចៗគ្នាទាំងអស់។ តែបើមានបុណ្យកុសលបានកើតមកជាមនុស្សពេញលក្ខណៈហើយ មិនបានបំពេញតួនាទីរបស់ខ្លួនចំពោះកិច្ចការងារសង្គម មិនចូលរួមអើពើចំពោះជាតិសាសន៍ខ្លួន មិនទំនាក់ទំនងសាធារជនទូទៅ និងរស់នៅគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន ឬ បក្សពួករបស់ខ្លួនជាដើម ។ល។ នោះហើយ ពិតជាជីវិតតែលតោល និង កេរ្តិ៍ឈ្មោះឥតមានន័យ សោកស្តាយយ៉ាងខ្លាំងចំពោះការរស់ នៅក្នុងសង្គមនៃឆាកជីវិតនៃយើង។ដើម្បីញ៉ាំងជីវិតរបស់យើងឱ្យមានកិត្តិយស និងមានតម្លៃថ្លៃថ្នូរនោះ យើងត្រូវតែមានស្មារតីចូលរួមកិច្ចការងារសង្គម និងលើកស្ទួយវិស័យវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ជាពិសេសមានសតិសម្បជញ្ញៈ ភ្ញាក់រំលឹកនឹកគិតដល់វាសនាសង្គមជាតិរបស់ខ្លួន ដែលកំពុងរងទុក្ខគ្រប់វិនាទី។ កត្តាសំខាន់ទៀតនោះ បងប្អូនប្រុសស្រី នៅក្នុងស្រុកនិងក្រៅស្រុកតែងតែខ្វល់ខ្វាយឈឺឆ្អាលរឿងជាតិខ្លួនឯង និងព្រះពុទ្ធសាសនាគ្រប់ៗអង្គនិងរូបទើបជីវិតនិងសង្គមជាតិយើងមានការវិវឌ្ឍន៍រីកចំរើននិងរុងរឿងទៅបាន។ ព្រះពុទ្ធបានសំដែងមកថា ការកើតមកជាមនុស្ស គឺជាការកម្រណាស់ ហេតុនេះ យើងខំបំពេញអំពើជាកុសលឱ្យបានច្រើនទើបធ្វើឱ្យជីវិតរបស់យើងមានខ្លឹមសារ ទាំងពេលបច្ចុប្បន្ន និងទៅអនាគត៕ ដោយ សឹង យ៉ឹង រតនា



# ហាងខ្មែរលក់មាស ឡាក់គី

# LUCKY JEWELRY

- មានលក់ពេជ្រ HRD, GIA, IGI គ្រប់មូដ
- មាសសន្លឹក 24K 999, Canada Credit Swiss
- គ្រឿងត្បូង South - Sea Pearl គ្រប់ជំពូក
- មានគ្រឿងអលង្ការនាំចូលថ្មីៗពីបរទេស
- មានរចនាមូដល្អៗទាន់សម័យនិយម
- ទិញចូលមានតម្លៃខ្ពស់
- លក់ចេញមានតម្លៃថោកសមរម្យ
- សូមអញ្ជើញអតិថិជនដោយមេត្រីភាព



- There are vast choices of models for HRD, GIA, IGI diamonds.

* 24K ... 999 flat-carded gold's are available from Canada Credit Swiss.
* All kind availabilities for gems and pearls from South-Sea Pearl.
* Newly imported jewelries from international countries.
* Modernize models are always updated.
* We buy your jewelries with high value offerings.
* We sell our jewelries with low, affordable pricing.
* **Please stop by, and we will guarantee your satisfaction!**

- **ម៉ោងធ្វើការ៖** Mon - Fri: 10:00am - 7:00pm
Tel: (408) 238-2098

- **2471 Alvin Ave. San Jose, CA 95121**
មានទទួល **Visa, Master Card** ៣ខែមិនគិតថ្លៃចុងការ

# មជ្ឈមណ្ឌលខ្មែរថែរក្សាភ្នែក SUNRISE

## Sunrise Medical-Dental Center

- មានវេជ្ជបណ្ឌិតស្ទាត់ជំនាញក្នុងការពិនិត្យភ្នែក។
- មានម៉ាស៊ីនទំនើបអាចវាស់ភ្នែកនិងកាត់កញ្ចក់វ៉ែនតា តាមតំរូវការ។
- មានវេជ្ជបណ្ឌិតនិយាយភាសាខ្មែរយ៉ាងស្ទាត់ជំនាញ។






Phone: (408) 227-6444
Fax: (408) 227-5056
www.kasod.com

DR. KENNETH A. WIENER
DR. STEVEN M. KAS
Optometrists

Eye Care/Lasik Consultations

Sunrise Medical-Dental Center
5710 Cahalan Avenue, Bldg. 2 San Jose, CA 95123

5710 Cahalan Avenue, Bldg.2
San Jose, CA 95123
Phone: (408) 227-6444
Fax: (408) 227-5056
www. Kasod.com

## ប្រវត្តិសង្ខេប នៃព្រះពុទ្ធសាសនា ចាប់កំណើតនៅលើទឹកដីសុវណ្ណភូមិ(តពីលេខមុន)

ជាព្រះសង្ឃនិងសិក្សាចំណេះដឹងពីពុទ្ធសាសនា ជាភាសាបាលីនៅកោះស្រីលង្កា ។ព្រះអង្គម្ចាស់តាមលិន្ទនឹងបានត្រឡប់មកកម្ពុជាវិញ ហើយបានផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋខ្មែរទៅតាមជំនឿបែបបទព្រះពុទ្ធសាសនា ដែលទ្រង់បានរៀនសូត្រ នឹងក្លាយទៅជាព្រះសង្ឃជាន់ខ្ពស់នៅសម័យនោះ ដោយការចេះដឹងរបស់ព្រះអង្គ។ នៅក្នុងរាជព្រះបាទជ័យវរ្ម័នទី៨ ព្រះពុទ្ធសាសនាត្រូវបានបំផ្លិចបំផ្លាញ រូបចម្លាក់បែបពុទ្ធសាសនា ត្រូវបានកោសលុប បំផ្លាញចោល ឬប្តូរទៅជារូបបែបព្រាហ្មណ៍វិញគេឃើញមានការវាយកម្ទេចព្រះពុទ្ធរូបចោល។

នៅក្នុងសម័យនោះ ពួកព្រាហ្មណ៍ទាំងអស់ត្រូវបានបង្កើតឡើងសារជាថ្មី និង ផ្តល់សិទ្ធិក្នុងការពង្រឹងសាសនានេះឡើងវិញផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយព្រះពុទ្ធសាសនា ត្រូវបានប្រជាពលរដ្ឋខ្មែរនិយមគោរពប្រតិបត្តិកាន់តែច្រើន។ការធ្វើបដិវត្តន៍សាសនាពីព្រាហ្មណ៍ទៅព្រះពុទ្ធសាសនានោះ មិនអាចធ្វើទៅរួចទេ។ដូចនេះសាសនាបានពួនសម្ងំនៅក្នុងស្រទាប់ប្រជាពលរដ្ឋខ្មែរ រហូតដល់រដ្ឋកាលត្រសក់ផ្អែមទើបមានការលើកស្ទួយវិស័យព្រះពុទ្ធសាសនា ឱ្យមានការរីកចំរើនឡើងវិញមកដល់សព្វថ្ងៃនេះ។

- ### ពុទ្ធសាសនាសម័យកណ្តាល

ក្រោយសតវត្សទី១៣មក ព្រះពុទ្ធសាសនាត្រូវបានលើកតម្កើងជាសាសនារបស់រដ្ឋ។ព្រះរាជាខ្មែរ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន គោរពស្រឡាញ់ព្រះពុទ្ធសាសនានេះខ្លាំងណាស់ និងមានជំនឿយ៉ាងមុតមាំ ដែលគេចាត់ទុកជាទីពឹងទីនឹករឭក ទោះជាប្រជាពលរដ្ឋខ្មែរមិនទាន់បោះបង់ចោលជំនឿលើព្រលឹង អារក្ខ អ្នកតាក៏




ដោយ ប៉ុន្តែចំពោះព្រាហ្មណ៍សាសនាពុំមានប្រជាពលរដ្ឋខ្មែរគោរពរាប់អានតទៅទៀតទេ។ ទោះជាយ៉ាងនេះក្តីក៏ទំនៀមទម្លាប់បែបព្រាហ្មណ៍ នៅតែជិតជាមក្នុងប្រពៃណីរបស់របស់ជនជាតិខ្មែររហូតដល់សព្វថ្ងៃ។ ឯក្នុងព្រះបរមរាជវាំងវិញគេនៅឃើញមានពួកព្រាហ្មណ៍បាគូនៅមានសេសសល់ក្នុងភារកិច្ចជាអ្នករៀបចំពិធីផ្សេងៗ និងថែរក្សាទ្រព្យសម្បត្តិរាជវាំងជាដើម។

ក្នុងសម័យនោះ ចំនួនវត្តអារាមបានកើនឡើងជាលំដាប់។ព្រះមហាថេរដែលមានតួនាទីមើលការខុសត្រូវលើការរៀបចំខាងសាសនា និងលើវត្តអារាមនៅក្នុងខេត្តនីមួយៗ លែងមានលទ្ធភាពបន្តការគ្រប់គ្រងនោះតទៅទៀតហើយ។ ដោយហេតុនោះសម្តេចសង្ឃរាជដោយមានការព្រមព្រៀងជាមួយរាជាគណៈ គ្រប់ឋានានុក្រមនិងសហការីទាំងអស់ ទ្រង់បានស្នើទៅព្រះរាជាសូមឱ្យមានការកែប្រែដែលមានបែងចែកដូចតទៅ៖

ព្រះមហាថេរមួយអង្គៗពីមុន(**តទៅទំព័រទី១១**)

# ត្រូវចេះប្រើប្រាក់ កុំអោយប្រាក់ត្របាក់យើង



មនុស្សគ្រប់វណ្ណៈទាំងអស់នៅសកលលោកនេះ ប្រាថ្នាតែភាពសុខសាន្ត ភាពរីកចំរើននឹងត្រូវការសង្គមមួយប្រកបដោយយុត្តិធម៌ សាមគ្គីធម៌ និងសំដែងការស្មោះត្រង់ជាមួយគ្នា។សង្គមគ្រួសារក្តី អង្គការសមាគមក្តី ប្រទេសជាតិក្តី សុទ្ធសឹងតែចង់បានភាពរីកចំរើនរុងរឿង ថ្កុំថ្កើង សំបូរសប្បាយទៅតាមសម័យនិយម តែមុននឹងទទួលនូវកត្តាទាំងនេះបានយើងត្រូវតែមានធនធាន(លុយ)ពេលវេលានិងផែនការច្បាស់លាស់ ដើម្បីរៀបចំគំរោងការ និងយុទ្ធសាស្រ្តឆ្ពោះទៅរកការអភិវឌ្ឍន៍សង្គម។

សម័យនេះអ្នកណាក៏ត្រូវការប្រាក់ទាំងអស់ មិនអាចគេចផុតឡើយ ពីព្រោះប្រាក់ជាមុខព្រួញមួយដ៏សំខាន់សំរាប់សំរេចគោលដៅ និង អ្វីដែលមនុស្សគ្រប់រូបត្រូវការចង់បាននោះ តែប្រាក់គេប្រៀបបានដូចជាកាំបិតមុខពីរ គឺជួយសំរេចបំណងដល់យើង នឹងក៏អាចបំផ្លាញឬសម្លាប់នូវកិត្តិយសយើងផងដែរ។ប្រសិនបើអ្នកទទួលការខុសត្រូវក្នុងការចាយវាយប្រាក់មិនចំទិសដៅ និងគ្មានតម្លាភាព ប្រាក់នឹងរុញច្រានខ្សែជីវិតយើងរាល់គ្នាឱ្យធ្លាក់ក្នុងជ្រោះជ្រៅ បាត់បង់កិត្តិសព្ទនឹងធ្វើឱ្យអ្នកជំនាន់ក្រោយឬក៏សង្គមទាំងមូលជួបបញ្ហាលំបាក។

ព្រោះយើងឃើញថា ប្រាក់ជារបស់បណ្តាលឱ្យបាននូវអ្វីៗគ្រប់យ៉ាង អាចទិញទឹកចិត្តមនុស្សបាន ក្នុងការប្រព្រឹត្តអំពើទុច្ចរិតខុសច្បាប់ខុសទម្លាប់យ៉ាងណាក៏ព្រមធ្វើទាំងអស់ឱ្យតែបានប្រាក់។ ហេតុដូច្នេះទើបនៅក្នុងលោកនេះ មានការឡើងកំដៅ ទាំងកំដៅចិត្ត និងកំដៅថ្ងៃ អ្នកណាក៏ដឹងដែរថា ប្រាក់មានសារសំខាន់ពិតមែនតែចូរយើងទាំងអស់គ្នាកុំសូវឱ្យសេចក្តីសំខាន់ដល់ប្រាក់ខ្លាំងពេក ក្រែងភ្លេចនូវអំពើល្អ ភ្លេចនូវគុណធម៌ និងភាពថ្លៃថ្នូររបស់ខ្លួនឯង។ កាលបើមនុស្សជាតិគ្រប់ឋានៈឱ្យតំលៃប្រាក់ហួសហេតុពេកនោះ ប្រាក់ត្រូវក្លាយទៅជាចៅហ្វាយនាយយើងជាក់ជាមិនខាន ពេលនោះ វានឹងចាប់ផ្តើមបង្វិលចិត្តគំនិតយើង ឱ្យបាត់បង់ស្មារតីដោយមិនដឹងខ្លួន។ យើងអាចពិនិត្យមើលខ្លួនឯង នៅពេលមិនទាន់មានលុយ ក៏មិនគិតចង់បានអ្វីប៉ុន្មានដែរ គឺចង់ទិញ ចង់ប្រើប្រាស់ របស់ណាចាំបាច់ប៉ុណ្ណោះមិនសូវមានការលោភលន់ទេ។ ព្រះពុទ្ធបានសំដែងមកថា មនុស្សសត្វទាំងអស់ ត្រូវខំព្យាយាមជៀសឱ្យផុតពីអកុសលធម៌ទាំងបីប្រការគឺ លោភៈ ទោសៈ និង មោហៈ។

យោងតាមការសិក្សាបានបង្ហាញថា មនុស្សយើងកាលមិនទាន់មានទ្រព្យសម្បត្តិ អាចមានពេលដេកពួនសំរាកសំរាន្តសុខស្រួលរាល់ថ្ងៃ តែដល់ពេលមានប្រាក់ច្រើន ត្រឡប់ទៅជារកឱកាសទំនេរមិនបានសូម្បីជួបជុំមិត្តភក្តិ ក្រុមគ្រួសារក៏លំបាកដែរ វាអាចធ្វើឱ្យសង្គមគ្រួសារខ្វះភាពកក់ក្តៅក៏ថាបាន ហួសដល់បុគ្គលខ្លះត្រូវអំណាចប្រាក់ត្របាក់យកសតិបញ្ញាអស់ពីខ្លួន ហើយឈានទៅរកភាពរឹករវ មិនស្គាល់បុណ្យ បាប អាក្រក់ ល្អ ស ខ្មៅ ស៊ូស្លាប់ដើម្បីប្រាក់ ប្រព្រឹត្តអំពើពុករលួយ កេងប្រវញ្ច័ទ្រព្យសម្បត្តិជាតិធ្វើស្រែលើខ្នងអ្នកជិតខាង ឬប្រជាពលរដ្ឋក្រីក្រជាដើម។

ហេតុនេះ យើងត្រូវតែសិក្សាស្រាវជ្រាវឱ្យបានច្បាស់លាស់ អំពីចិត្តលោភ និងចិត្តល្ងង់ខ្លៅ កុំឱ្យទឹកប្រាក់បញ្ជាឬធ្វើម្ចាស់មកលើរូបយើង គឺយើងទេជាអ្នកប្រើប្រាស់វា តែប្រើក្នុងផ្លូវត្រូវ យ៉ាងនេះទើបមិនមានការក្តៅក្រហាយនៅពេលក្រោយ។..**(តទៅទំព័រទី១៥)**

(តមកពីទំព័រទី១)
ប៉ះចំថ្ងៃ១៤មេសាដែរ។ មហាសង្រ្កាន្តដែលប្រើគន់គូរតាមសុរិយគតិមានឈ្មោះថា **សាមញ្ញសង្រ្កាន្ត** គឺព្រះអាទិត្យដើរចំត្រង់ពីលើក្បាលជាសង្រ្កាន្ត។ ចំណែកមហាសង្រ្កាន្តដែលគន់គូរតាមចន្ទគតិ មានឈ្មោះថា **អាសន្នសង្រ្កាន្ត**គឺព្រះអាទិត្យដើរបញ្ចៀសមិនចំពីលើក្បាលទេ។ គេនឹងប្រើចន្ទគតិអែបជាប់ជាមួយសុរិយគតិ មិនអាចលុបចោលបានទេ ដោយសារចន្ទគតិមានទំនាក់ទំនងនឹងពុទ្ធប្បញ្ញត្តិជាច្រើន។

បុណ្យចូលឆ្នាំថ្មី គឺជាបុណ្យមួយមានសារៈប្រយោជន៍ខ្លាំងណាស់នឹងមានភាពសប្បាយរីករាយគួរជាទីពេញចិត្តសំរាប់ប្រជាមិត្តពុទ្ធបរិស័ទទូទៅ ក្នុងការរាបចំផ្ទះសំបែង មានផ្កាភ្ញីចំរុះពណ៌ ផ្លែឈើគ្រប់មុខ និងគ្រឿងសក្ការៈបូជាផ្សេងៗ ដើម្បីទទួលទេវតាឆ្នាំថ្មី សូមសុខសួស្តី ជោគជ័យមហាប្រសើរសំរាប់សង្គមគ្រួសារព្រមទាំងប្រទេសជាតិផងដែរ។

ទាក់ទងនឹងប្រវត្តិបុណ្យចូលឆ្នាំខ្មែរនេះ នៅក្នុង**មហាសិការសូត្រ**បានសំដែងថា៖ កាលដើមកទ្ទកប្បនេះមានបុរសម្នាក់ឈ្មោះ**ធម្មបាល** ជាបុត្តសេដ្ឋី មានចំណេះវិជ្ជាខ្ពង់ខ្ពស់ រៀនចប់គម្ពីរត្រៃវេទតាំងពីអាយុ៧ឆ្នាំ ចេះចាំទាំងភាសាបក្សាបក្សីស្តាប់សំឡេងសត្វយំបានទៀតផង និងជាអ្នកមានទឹកចិត្តសប្បុរស ព្រមទាំងជាអ្នកសំសំដែងមង្គលផ្សេងៗ ដល់មនុស្សទាំងពួងផង។

គ្រាមួយនោះ កបិលមហាព្រហ្មជ្រាបជាព័ត៌មានបានចុះមកសួរបញ្ហានិងធម្មបាលនូវប្រស្នា៣ខ ដោយសន្យាថា បើដោះរួចសុខចិត្តកាត់ក្បាលបូជាធម្មបាលកុមារ តែបើដោះមិនរួចនឹងកាត់ក្បាលធម្មបាលកុមារវិញ។រយៈពេល៧ថ្ងៃក្រោយមកធម្មបាលកុមារនឹងដោះស្រាយប្រស្នានោះរួច កបិលមហាព្រហ្មក៏កាត់ព្រះកេសាថ្វាយដល់ធម្មបាលកុមារ។ប្រស្នា៣ខនោះគឺ៖

ក/ពេលព្រឹកសិរីសួស្តីស្ថិតនៅត្រង់ណា?ឆ្លើយថាស្ថិតនៅត្រង់មុខ។

ខ/ពេលថ្ងៃត្រង់សិរីសួស្តីស្ថិតនៅត្រង់ណា? ឆ្លើយថាស្ថិតនៅត្រង់ដើមទ្រូង។

គ/ពេលរសៀលសិរីសួស្តីស្ថិតនៅត្រង់ណា?ឆ្លើយថាស្ថិតនៅត្រង់ជើង។

តែមុននឹងកាត់ក្បាល កបិលមហាព្រហ្មបានកោះហៅទេពធិតាទាំង៧នាក់មកជួបជុំគ្នា ហើយក៏កាត់ព្រះកេសហុចទៅឲ្យនាងទុង្សាជាកូនច្បង នាងបានយកពានទទួលព្រះកេសាបិតា រួចដង្ហែប្រទក្សិណភ្នំព្រះសុមេរុ៦០នាទី ទើបយកទៅប្រតិស្ឋានទុកក្នុងមណ្ឌលគុហាគន្ធមាលី ភ្នំកៃឡាសបូជាគ្រឿងទិព្វផ្សេងៗព្រះវិស្សកម្មទេវបុត្រក៏និមិត្តរោងទិព្វ ប្រកបដោយកែវ៧ប្រការឈ្មោះថា«ភគវតីសភា»ឲ្យជាទីប្រជុំនៃទេវតាលុះដល់គំរប់១ឆ្នាំជាសង្រ្កាន្តនាងទេពធិតាទាំង៧ផ្លាស់វេនគ្នាមកអញ្ជើញព្រះកេសកបិលមហាព្រហ្មចេញមកហែប្រទក្សិណភ្នំព្រះសុមេរុរាល់ៗឆ្នាំ ហើយត្រឡប់ទៅកាន់ស្ថានទេវលោកវិញ។ សូមបញ្ជាក់ថា ក្បាលមហាព្រហ្មមានឫទ្ធានុភាពខ្លាំងណាស់ បើដាក់នៅផែនដីនឹងមានភ្លើងឆេះទាំងលោកធាតុ បើបោះទៅលើអាកាសភ្លៀងក៏រាំងបើបោះទៅក្នុងទឹកសមុទ្រនឹងរីងស្ងួតអស់ ដូច្នេះទើបកូនទាំង៧នោះដាក់វេនគ្នាថែរក្សាជារៀងរាល់ឆ្នាំ គឺមិនអាចធ្វេសប្រហែសបានឡើយ។

បុណ្យចូលឆ្នាំខ្មែរ តាមទំនៀមទម្លាប់ គឺប្រព្រឹត្តទៅរយៈពេលបីថ្ងៃ៖

- ថ្ងៃដំបូងជាថ្ងៃមហាសង្រ្កាន្ត នៅតាមផ្ទះនីមួយៗត្រូវរៀបចំឲ្យស្អាត ដើម្បីរងចាំទទួលទេវតាឆ្នាំថ្មី ដែលជាអ្នកទទួលបន្ទុកថែរក្សាមនុស្សជាតិ។
- ថ្ងៃទីពីរ ជាថ្ងៃវ័នបត(គឺថ្ងៃកណ្តាល ចែកឆ្នាំចាស់និងឆ្នាំថ្មី) ត្រូវរៀបចំម្ហូបអាហារ ,គ្រឿងបរិក្ខាផ្សេងៗសំរាប់ជូនចំពោះមាតាបិតា ជីដូនជីតារបស់ខ្លួន និងចូលរួមបរិច្ចាគទ្រព្យធនដាក់ទានដល់ជនក្រីក្រ អ្នកទុគ៌តជាដើម។ ថ្ងៃទីពីរនេះទៀតសោត គឺមានការរៀបចំពូនភ្នំខ្សាច់ ហៅថា **វាលុកចេតិយ** ក្នុងន័យ**(តទៅទំព័រទី១៥)**

# រក្សាកាយវាចាចិត្ត ជីវិតឧត្តម

មនុស្សគ្រប់ៗរូបទាំងអស់សុទ្ធសឹងតែប្រាថ្នាចង់បានជីវិតមួយ ប្រកបដោយសុភមង្គលឬជីវិតឧត្តុង្គឧត្តម សំរាប់សង្គមគ្រួសារ ជាធម្មតាខ្សែជីវិតមនុស្សយើងមានការប្រែប្រួល និង វិលវល់គ្រប់កាលៈទេសៈទាំងអស់ បើគ្មានផែនការរៀបចំកាយ វាចា ចិត្ត ឱ្យល្អប្រសើរនោះ។

កាយ វាចា ចិត្ត របស់យើងពល់គ្នា ប្រសិនបើបានហ្វឹកហាត់ល្អហើយ ប្រៀបបានដូចជាគ្រឿងប្រដាប់សំរាប់លើកស្ទួយនូវបុគ្គលិកលក្ខណៈ នៃខ្លួនយើងឱ្យប្រសើរខ្ពង់ខ្ពស់ គួរគោរពរាប់អានពីសំណាក់អ្នកផងទាំងពួង។ មនុស្សយើងមិនអាចល្អបានដោយឯងៗនោះទេ គឺត្រូវតែធ្វើការបណ្តុះបណ្តាល ឬ អប់រំបន្ទាន់ចិត្តទៅតាមបែបបទនៃទ្រឹស្តីព្រះពុទ្ធសាសនា ដូចជាការធ្វើសមាធិដើម្បីអូសទាញអារម្មណ៍របស់ខ្លួនឱ្យនឹងមូលជាឯកតារម្មណ៍ ក្នុងការបង្កើតបញ្ញាសំរាប់ចង្អុលបង្ហាញផ្លូវទៅរកភាពរីកចំរើន នៃផាកជីវិតបច្ចុប្បន្ន នឹងបានជាប់ជាឧបនិស្ស័យតទៅជាតិមុខទៀតនោះ។

ព្រះសម្មាសម្ពុទ្ធព្រះអង្គសំដែងថា ពុទ្ធិ និងការប្រព្រឹត្តល្អ ព្រមទាំងសេចក្តីស្ងប់រម្ងាប់ផ្លូវចិត្តគឺជាខ្លឹមសារនៃជីវិត ដូច្នេះយើងគួរតែស្វែងរកខ្លឹមសារទាំងនេះ មកទុកដណ្តាប់លើចិត្តរបស់ខ្លួន ទើបជីវិតមានន័យពិតប្រាកដ។ ការកើតជាមនុស្សគឺជាការកម្រណាស់ តែបើបានកើតមកហើយ ត្រូវខំសាងអំពើសុចរិតឱ្យច្រើន ចេះបែងចែកពេលវេលា ដែលមានតំលៃទុកសំរាប់ជួយកិច្ចការងារសង្គមជាពិសេសត្រូវចេះចែករំលែកទ្រព្យធនជួយកសាងសង្គមជាតិ ព្រះពុទ្ធសាសនានិងអ្នកក្រីក្រ ទុគ៌ត កំសត់អត់ឃ្លាន កាលបើអនុវត្តន៍បានត្រឹមត្រូវនោះ កាយ វាចា ចិត្ត នឹងមានភាពត្រជាក់ត្រជុំ ទន់ភ្លន់ រមទម្យ សមជាកូនខ្មែរអ្នកមានពូជអំបូរ មានវប្បធម៌ ប្រពៃណីថ្លៃថ្នូរ។

ដើម្បីរក្សាកាយ វាចា ចិត្ត ឱ្យប្រសិទ្ធិភាពខ្ពស់ទៅបាន យើងត្រូវប្រតិបត្តិគោលធម៌ **ឃរាវាធម៌** ទាំង៤ប្រការគឺ៖

- **សច្ចៈ** ស្មោះត្រង់ជាមួយគ្នាទៅវិញទៅមកមិនត្រូវក្បត់គ្នា រក្សាចិត្តគំនិតឱ្យនឹងន។
- **ទមៈ** រក្សាហ្វឹកហាត់ទូន្មានចិត្តជារៀងរាល់ថ្ងៃកុំសាងនូវសេចក្តីប្រមាថ។
- **ខន្តិ** ចេះអត់ធន់ តស៊ូ ពុះពារមិនខ្លាចលំបាកទោះបីជួបបញ្ហាអ្វីក៏ដោយត្រូវហ៊ានប្រឈមមុខដោះស្រាយតាមផ្លូវច្បាប់
- **ចាគៈ** ចេះដាក់ទានទៅតាមសមត្ថភាព ដែលខ្លួនមាន និងចេះលះបង់ខ្ពស់។

សរុបមក ប្រសិនជាមនុស្សគ្រប់រូប បដិបត្តិគោលធម៌ទាំង៤ខាងលើបានល្អនោះ ជីវិតពិតជាមានសេចក្តីសុខចំរើន តាមវិស័យជាបថុជ្ជជនដែលជាបុគ្គលល្អ៕ ដោយ **ស៊ឹម ចន្ទ្រា**

# វៀតណាមបដិសេធមិនឲ្យព្រះសង្ឃខ្មែរក្រោម១អង្គចូលស្រុក

ព្រះសង្ឃខ្មែរក្រោម១អង្គ ព្រះនាម ថាច់ វាសនា ព្រះជន្ម ២៩ព្រះវស្សា ដែលធ្វើដំណើរតាមជើងយន្តហោះពីក្រុងបាងកកទៅកាន់ក្រុងហូជីមិញ ត្រូវបានប៉ូលិសវៀតណាមនៅព្រលានយន្តហោះឃាត់ខ្លួន នៅថ្ងៃទី១ មេសានេះ និងបង្ខំឲ្យឡើងយន្តហោះត្រឡប់ទៅក្រុងបាងកកវិញ។ ព្រះសង្ឃខ្មែរកម្ពុជាក្រោម ថាច់ វាសនា បានមានព្រះថេរដីកាតាមទូរស័ព្ទពីទីក្រុងហូជីមិញឲ្យដឹងថា ក្រោយពេលមកបួសរៀននៅក្រុងភ្នំពេញ ព្រះអង្គបានចាកចេញទៅរៀនបន្តវិជ្ជានៅក្រុងបាងកកប្រទេសថៃ រយៈពេល ៣ឆ្នាំ ហើយនៅថ្ងៃទី១ មេសានេះ ព្រះអង្គក៏បាននិមន្តចេញពីបាងកកទៅក្រុងហូជីមិញ ប្រទេសវៀតណាម ដើម្បីទៅលេងស្រុកកំណើតនៅភូមិជ្រៃតាស ឃុំដើមជ្រៃ ស្រុកមាត់សមុទ្រ ខេត្តព្រះត្រពាំង ប្រទេសវៀតណាម។ ព្រះអង្គមានលិខិតឆ្លងដែនកម្ពុជាក្នុងការធ្វើដំណើរនោះ។ ព្រះសង្ឃ ថាច់ វាសនា មានព្រះថេរដីកាឲ្យដឹងទៀតថា ព្រះអង្គមិនព្រមឡើងយន្តហោះទៅប្រទេសថៃវិញទេ ព្រោះព្រះអង្គមិនមានកំហុសអ្វីទេ ៖ *«ឥឡូវគេមិនឲ្យអាត្មាចូលស្រុក អាត្មាចេញពីបាងកកហ្នឹង មកដល់នេះម៉ោង៩ ថ្ងៃទី១ ខែ៤។ អាត្មាមកពីបាងកក មកទីក្រុងព្រៃនគរ ហើយទៅលេងស្រុកកំណើតនៅខេត្តព្រះត្រពាំង។ អាត្មាទៅរៀននៅបាងកក ៣ឆ្នាំហើយ ពេលនេះអាត្មានិមន្តមកលេងស្រុក។ ឥឡូវមកដល់ព្រលានយន្តហោះត្រូវបានប៉ូលិសព្រលានឃុំឃាំង មិនឲ្យអាត្មាចូលស្រុក។ គេដេញឲ្យអាត្មាត្រឡប់ទៅបាងកកវិញ ហើយអាត្មាមិនទាន់ព្រមទៅ អាត្មានៅតាំបន្តិច...»*។ ព្រះសង្ឃ ថាច់ វាសនា បានមានព្រះថេរដីកាបន្តថា ៖ *«...មូលហេតុគេថា បញ្ហាសន្តិសុខមិនអាចទទួលអាត្មាហ្នឹងឲ្យនៅក្នុងប្រទេសគេបានទេ គេថាអ៊ីចឹង ហើយអាត្មាបាននិយាយប្រាប់គេថា កន្លែងហ្នឹងគឺជាប្រទេសកំណើតរបស់អាត្មាដែរ អ៊ីចឹងអាត្មាទៅសិក្សារៀនសូត្រ ហើយត្រឡប់មកវត្តវិញ សួរសុខទុក្ខគ្រូ ញាតិញោម បងប្អូនឪពុកម្ដាយអ៊ីចឹងទៅណា! គេថា គេមិនអាចទទួលបានទេ ឲ្យអាត្មាត្រឡប់ទៅកន្លែងដើមវិញ គឺទីក្រុងបាងកក»*។

ព្រះសង្ឃ ថាច់ វាសនា បានមានព្រះថេរដីកាបន្ថែមថា ព្រះអង្គបានសុំអាជ្ញាធរវៀតណាមដើម្បីជួបជាមួយអ្នកការទូតខ្មែរដែរ ប៉ុន្តែគេមិនអនុញ្ញាតឲ្យជួបទេ។ មកទល់នឹងពេលនេះ មិនទាន់មានការពន្យល់បកស្រាយណាមួយពីសំណាក់អាជ្ញាធរវៀតណាមនៅឡើយទេ៕

*ប្រកពពី RFA /04-01-2010*

## ដំណឹងសិក្សា
## ភាសាខ្មែរ និងរបាំប្រពៃណីបុរាណខ្មែរ

ពុទ្ធិកសមាគមខ្មែរក្រោម **វត្តខេមររង្សី** និង**ក្រុមរបាំអប្សរា** នៅទីក្រុងសាន់ហូសេ្ស មានកិត្តិយសសូមជំរាបជូនដំណឹងដល់បងប្អូនជនរួមជាតិខ្មែរ គ្រប់មជ្ឈដ្ឋាន ឲ្យបានជ្រាប សូមទានជ្រាប ៖

*** កម្មវិធីសិក្សាភាសាខ្មែរ ជារៀងរាល់ថ្ងៃសុក្រ និងសៅរ៍ ចាប់ពីម៉ោង **4:00PM - 5:00PM**

*** កម្មវិធីបង្ហាត់របាំប្រពៃណីខ្មែរ ជារៀងរាល់ថ្ងៃសុក្រ ចាប់ពីម៉ោង **6:00PM - 8:00PM**

អាស្រ័យហេតុនេះ សូមអញ្ជើញអាណាព្យាបាល និងសិស្សានុសិស្ស គ្រប់ស្រទាប់វណ្ណៈ ដែលមានទឹកចិត្តស្រឡាញ់ និងលើកស្ទួយវិស័យវប្បធម៌ខ្មែរ មេត្តារួសរាន់នាំបុត្តធីតារបស់លោក អ្នក មកសិក្សាភាសាខ្មែរ និងរបាំប្រពៃណីជាតិ ដោយសោមនស្សរីករាយ។

*** **ទីកន្លែង:** វត្តខេមររង្សី **1594 Cunningham Ave, San Jose. CA 95122 Tel: (408) 923-2166**

(តមកពីទំព័រទី៦)

ឥឡូវត្រូវតែងតាំងជាមេគណទទួលខុសត្រូវ លើគណៈព្រះមហាថេរមួយអង្គៗពីមុន គឺត្រូវជ្រើសរើសទៅជាមេគណទទួលខុសត្រូវលើគណៈសង្ឃក្នុងខេត្តនីមួយ។ ចំណែកឯព្រះរាជាគណៈទាំង៤និង សម្តេចព្រះសង្ឃរាជ ជាអ្នកត្រួតពិនិត្យសំរេចកិច្ចការសាសនា ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល។ រាជាគណៈឬមន្ត្រីសង្ឃទាំង៤ថ្នាក់នោះ ត្រូវបែងចែកជា ឯក ទោត្រី ចត្វា ដូចមន្ត្រីជាន់ខ្ពស់ខាងផ្នែកអាណាចក្រដែរ។

-សំរាប់ឯក ជារាជាគណៈរបស់ក្សត្រិយ៍ទ្រង់រាជ្យ។

-សំរាប់ទោ ជារាជាគណៈរបស់ក្សត្រិយ៍ឧភយោរាជ។

-សំរាប់ត្រីជារាជាគណៈរបស់សម្តេចព្រះមហាឧបរាជ។

-សំរាប់ចត្វាជារាជាគណៈរបស់សម្តេចព្រះវររាជិនី។

(សៀវភៅលោកត្រឹងងារប្រវត្តិសាស្ត្រខ្មែរភាគ២)។

ព្រះពុទ្ធសាសនា ក៏ដើរតួយ៉ាងសំខាន់ផងដែរក្នុងវិស័យអក្សរសាស្ត្រ និងការតាក់តែងនិពន្ធ។ ហេតុនេះហើយទើបឃើញកើតមានជាអត្ថបទគម្ពីរបិដក ជាតកច្រើនកើតឡើងហូរហៃ។មិនតែប៉ុណ្ណោះទេអត្ថន័យបែបព្រះពុទ្ធសាសនា ពោលគឺ ទស្សនៈពុទ្ធនិយម ត្រូវបានអ្នកនិពន្ធខ្មែរយកមកធ្វើជាវិធីសាស្ត្រ ក្នុងការតាក់តែងអត្ថបទរបស់ខ្លួនផងដែរ។ ព្រឹត្តិការណ៍ទាំងអស់នេះបានកើតឡើងនៅក្រោយពេលដែលទីក្រុងអង្គរត្រូវបានព្រះរាជាខ្មែរបោះបង់ចោល ហើយប្រទេសធ្លាក់ចូលទៅក្នុងកលិយុគ ចម្បាំងកើតមានញឹកញាប់។ ការលើកយកទស្សនៈបុណ្យបាប របស់ពុទ្ធសាសនាមកកែច្នៃឬតាក់តែងជាស្នាដៃអក្សរសិល្ប៍នេះ គឺត្រូវបានអ្នក



*ប្រជាជនខ្មែរ-ខ្មែរក្រោម គោរពប្រតិបត្តិព្រះពុទ្ធសាសនា*

សិក្សាខ្លះវិភាគថា ជាការលើកទឹកចិត្តដល់ប្រជាពលរដ្ឋខ្មែរជាការលួងលោមកុំឱ្យពួកគាត់ធ្លាក់ទឹកចិត្ត បាក់ទឹកចិត្តដោយចាត់ទុកហេតុការណ៍រីទុក្ខលំបាកវេទនាដែលខ្លួនជួបប្រទះនេះ ជាកម្មពៀររបស់ខ្លួន ដែលបានសាងមកពីអតីតជាតិ។ ព្រះសង្ឃក្នុងពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សា អក្សរសិល្ប៍ អក្សរសាស្ត្រជាតិ និងប្រពៃណីទំនៀមទម្លាប់របស់ខ្មែរឱ្យនៅគង់វង្ស។ ចំពោះវិស័យសង្គមកិច្ចវិញព្រះសង្ឃជាគ្រូពេទ្យ ជាអ្នកកាត់ក្តី ជាអ្នកមើលការខុសត្រូវដល់ប្រជាពលរដ្ឋខ្មែរ។ ទីធ្លាវត្តអារាមបានក្លាយទៅជាទីសំរាប់ជនទុគ៌តសំរាកនិងព្យាបាលជម្ងឺផ្លូវចិត្ត។ ការសន្តោសរបស់ព្រះសង្ឃ គឺជាការចូលរួមចំណែកក្នុងវិស័យសង្គមជាតិនឹងបានធ្វើឱ្យព្រះពុទ្ធសាសនាកាន់តែទទួលស្គាល់និងគោរពប្រតិបត្តិពីប្រជាពលរដ្ឋខ្មែរកាន់តែច្រើនឡើង។

- **ពុទ្ធសាសនាសម័យអាណានិគមបារាំង**

សម័យអាណានិគមនិយមបារាំងគិតចាប់ពីឆ្នាំ១៨៦៣នៅពេលដែលព្រះនរោត្តម (តទៅលេខក្រោយ)

# ប្រវត្តិសង្ខេប នៃការកសាងវត្តខ្មែរអូកឡិនដ៍

ប្រជាពលរដ្ឋខ្មែរយើង ជាអ្នកគោរពប្រតិបត្តិព្រះពុទ្ធសាសនាតាំងពីបុរាណកាលមកម្ល៉េះទោះបីប្រទេសជាតិជួបវិបត្តិនយោបាយ គឺភ្លើងសង្គ្រាមយ៉ាងណាក្តី ប្រជាជនខ្មែរនៅតែមានទឹកចិត្តគោរពស្រឡាញ់និងការពារថែរក្សានូវប្រពៃណី ទំនៀមទម្លាប់ អក្សរសាស្ត្រ សាសនារបស់ខ្លួនគ្រប់ពេលវេលា។

ដោយឡែកប្រជាពលរដ្ឋខ្មែរ ដែលបានឃ្លាតឆ្ងាយពីស្រុកកំណើតមករស់នៅទីក្រុង Oakland នៃរដ្ឋ California សហរដ្ឋអាមេរិកបានរួបរួមគ្នាបង្កើតជាសមា



វត្តខ្មែរអូកឡិនដ៍ នៅទីក្រុង Oakland នៃរដ្ឋ California ក្នុងឆ្នាំ២០១០

គមមួយ ឈ្មោះថា **ពុទ្ធិកសមាគមខ្មែរអូកឡិនដ៍** ក្នុងឆ្នាំ ១៩៨៣ ក្នុងទិសដៅទ្រទ្រង់និងថែរក្សាអត្តសញ្ញាណជាតិកុំឲ្យបាត់បង់។ ដោយសារបងប្អូនខ្មែរយើងមករស់នៅទីក្រុងOakland កាន់តែច្រើនឡើង ទើបគណៈកម្មការ ពុទ្ធិកសមាគមសំរេចកសាងវត្តមួយ ឈ្មោះថា **វត្តខ្មែរអូកឡិនដ៍** ក្នុងឆ្នាំ១៩៨៩ ដើម្បីអោយពុទ្ធបរិស័ទធ្វើបុណ្យទាន និង ជាកន្លែងសម្រាប់បណ្តុះបណ្តាលនូវប្រពៃណី វប្បធម៌ អក្សរសាស្ត្រខ្មែរ ព្រមទាំងបង្ហាញឲ្យសាសន៍ដទៃបានស្គាល់អំពីតំលៃនៃអរិយធម៌ខ្មែរព្រមទាំងផ្សព្វផ្សាយនូវឳវាទព្រះពុទ្ធបរមគ្រូនៃយើងឱ្យសាសនិកជនទូទៅបានយល់ដឹងអំពីផលបុណ្យ ផលបាប អប់រំផ្លូវចិត្តឱ្យស្គាល់ពីជីវិតពិត និងកសាងកម្លាំងសាមគ្គីនៅក្នុងសង្គមខ្មែរ។តែគួរឱ្យសោកស្តាយ នៅខែ៦ឆ្នាំ



វត្តខ្មែរអូកឡិនដ៍ នៅទីក្រុង Oakland នៃរដ្ឋ California ក្នុងឆ្នាំ១៩៩០

២០០៤ ដោយមានបុគ្គលអគតិមួយក្រុមតូចមិនស្មោះត្រង់នឹងវត្តបានបង្ករអស្ថេរភាពមិនឈប់ឈរហូតដល់ខែ១ឆ្នាំ២០០៥ពួកគេរួមដៃនឹងមន្ត្រីសង្ឃខ្មែរអន្តរជាតិមកគ្រប់គ្រងវត្តខ្មែរអូកឡិនដ៍ទាំងទទឹងទិស នឹងបានធ្វើការផ្លាស់ប្តូរថ្នាក់ដឹកនាំវត្ត។កត្តានេះហើយធ្វើឱ្យព្រះតេជគុណ **ធម្មសារ សម សុន** ព្រះសង្ឃ គណៈកម្មការវត្តនិងពុទ្ធបរិស័ទដែលជាអ្នកផ្តួចផ្តើមប្រមូលសទ្ធាជ្រះថ្លាពីសប្បុរសជនទាំងអស់ ដើម្បីជាវវត្តខ្មែរអូកឡិនដ៍មានការហួសចិត្ត និងឈឺចាប់យ៉ាងខ្លាំងមិនអាចបំភ្លេចបាន។គួរឱ្យអនិច្ចាព្រះតេជគុណ **ធម្មសារ សម សុន** ព្រះចៅអធិការវត្ត ព្រះអង្គបានទទួលអនិច្ចធម្មកាលពីឆ្នាំ ២០០៥ នៅរដ្ឋ Florida ដោយសារការពាក់ព័ន្ធនឹងផ្លូវចិត្ត។

ចាប់ពីពេលនោះមក ក្រុមអតីតគណៈកម្មការ និងពុទ្ធបរិស័ទ បានអញ្ជើញទៅកាន់ការិយាល័យមន្ត្រីសង្ឃខ្មែរអន្តរជាតិនៅរដ្ឋ Massachusetts ដើម្បីធ្វើការចរចាដោះស្រាយដោយសន្តិវិធីជាច្រើនលើកតែមិនបានទទួលលទ្ធផលជាវិជ្ជមានឡើយ។ ហេតុនេះហើយទើបធ្វើឱ្យពុទ្ធបរិស័ទទាំងនោះ មិនសប្បាយចិត្តទើបសំរេចរកមេធាវីប្តឹងទៅតុលាការតាមផ្លូវច្បាប់ដើម្បីរកយុត្តិធម៌ប្រគេន-ជូន ចំពោះព្រះតេជគុណ **ធម្មសារ សម សុន** ព្រះសង្ឃនិងពុទ្ធបរិស័ទដែលជាសមាជិក-ការវត្ត។

ការប្តឹងទៅតុលាការ......... (**តទៅទំព័រទី១៤**)

# ជំនឿរបស់ខ្មែរមុនការទទួលយកព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា

ប្រជាពលរដ្ឋខ្មែរ ជាជនជាតិមួយដែលមានចំណាស់បំផុត រីឯវប្បធម៌ និងអរិយធម៌ក៏ដូច្នោះដែរ។ ប៉ុន្តែគួរឱ្យសោកស្តាយ រហូតមកដល់សព្វថ្ងៃនេះ មិនទាន់ឃើញមានឯកសារខាងបុរាណវិទ្យាណាមួយ បានស្រាវជ្រាវអំពីជំនឿសាសនាពីសម័យបុរេប្រវត្តិសាស្រ្តនោះទេ។ មានសៀវភៅជាច្រើនបាននិពន្ធនិងរៀបរាប់ខ្លះៗដែរ ប៉ុន្តែគ្រាន់តែអត្ថាធិប្បាយអំពីព្រហ្មញ្ញសាសនា - ព្រះពុទ្ធសាសនា ដែលហូរចូលមកដល់ដែនដីខ្មែរនាដើម ស.វទី១នៃគ.សហើយជំនឿសាសនា ដែលមានមុនការនាំចូលនៃសាសនាទាំងពីរនេះ ត្រូវគេបោះបង់ចោល មិនបានស្រាវជ្រាវឱ្យដិតដល់។តាមការពិត កង្វះខាតនេះបណ្តាលមកពីទស្សនៈមួយដែលយល់ថា មុនវត្តមានព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា គ្មានជំនឿសាសនាទេ ហើយអ្វីដែលមាននោះ សុទ្ធតែជាជំនឿសាសនាអកុសលឬហៅថាអបិយជំនឿទាំងអស់។

យោងតាមប្រភពនៃការស្រាវជ្រាវ របស់អ្នកប្រាជ្ញខ្មែរបានបញ្ជាក់ថាវប្បធម៌ អរិយធម៌ខ្មែរ និងជំនឿសាសនាទាក់ទិនទៅនឹងធម្មជាតិ ទឹកដីជាដើម។ ថ្វីត្បិតតែប្រជាជនខ្មែរយើងសព្វថ្ងៃនេះគោរពប្រណិប័តន៍ព្រះពុទ្ធសាសនាក៏ពិតមែន តែពួកគេនៅតែបន្តជំនឿសាសនាដើមបែបជីវចរនិយមរបស់ខ្លួនផ្ទាល់ ដែលមានអាយុច្រើនពាន់ឆ្នាំមុនសម័យប្រវត្តិសាស្រ្តមកម្ល៉េះ ហើយសំណង់វប្បធម៌អរូបីនេះ បានវិវត្តពីយុគមួយទៅយុគមួយទៀត ដោយមានការទាក់ទងនឹងវប្បធម៌ឥណ្ឌា ចិននិងចក្រភពក្រិច រ៉ូម៉ាំងនាដើមស.វទី១ នៃគ.ស។ ជំនឿសាសនាបច្ចុប្បន្នរបស់ខ្មែរ មានលក្ខណៈជាវប្បធម៌សំយោគ ដែលអាចចាត់ទុកថាជាម៉ុត្រីកោណមួយនេះ គឺជាលទ្ធផលនៃការបូក



វត្ថុសំរាប់គោរពបូជារបស់ប្រជាជនខ្មែរ មុនទទួលយកព្រះពុទ្ធសាសនា

ផ្សំគ្នារវាងអ្វីដែលជាលក្ខណៈ មន-ខ្មែរបែបជីវចរនិយម និងសមាសភាពឬធាតុឥណ្ឌា ដែលមានប្រភពចេញពីលទ្ធិព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។ការសិក្សាស្រាវជ្រាវនេះពឹងផ្អែកទៅលើការវិភាគអំពីកំណាយស្ថានីយបុរេប្រវត្តិសាស្រ្ត ព្រមទាំងសិក្សាតាមរយៈពិន្ទុវិទ្យានៃជនជាតិខ្មែរនិងកុលសម្ព័ន្ធខ្មែរលើដែលពុំបានទទួលឥទ្ធិពលពីក្លិង្គ ហើយបានថែរក្សាជំនឿ ប្រពៃណីដូនតាតាំងពីសម័យបុរាណកាលមក។

មុនសម័យប្រវត្តិសាស្រ្ត ជនជាតិខ្មែរគោរពព្រះ (ពាក្យខ្មែរ)ទេវតាឬអាទិទេព ដែលពុំមានរូបរាងច្បាស់លាស់ ដូចជាដី ទឹក ភ្លើង ខ្យល់ជាដើម ពីព្រោះពួកគេជឿថាធម្មជាតិទាំងឡាយ ដែលស្ថិតនៅជុំវិញខ្លួនសុទ្ធសឹងតែមានព្រលឹងដ៏មានឫទ្ធានុភាព ឬភាពសក្តិសិទ្ធិ អាចនឹងផ្តល់ឲ្យពួកគេ ទទួលបានសេចក្តីសុខសប្បាយ ហេតុនេះបានជាគេសូនរូបសត្វ គោ ក្របី ស្វា....ឬយកថ្មនិងព្រៃព្រឹក្សាមកគោរពបូជា ដើម្បីសុំសុខចំរើន។ការបូជាវត្ថុ និង សត្វមានជីវិតដែលជាតំណាងធាតុឬសារជាតិអ្វីមួយ គេបានប្រឌិតនូវសត្វអច្ឆរិយៈដែរ។ ថ្ម ដើមឈើ សត្វ ឬធម្មជាតិទាំងនោះ គេបានចាត់ទុកជាកេតនភណ្ឌតំណាងនូវអ្វីដែលខ្ពស់បំផុត អាចជួយសង្រ្គោះពេលមានអាសន្នឬមានគ្រោះថ្នាក់ម្តងៗ។

គួរពិចារណាផងដែរថា ការបូជាសត្វពុំមែនមានន័យថា សត្វជាសត្វទេក៏ប៉ុន្តែជាឥទ្ធិ(**តទៅទំព័រទី២៤**)

(តមកពីទំព័រទី១២)អស់រយៈពេលជាច្រើនឆ្នាំលុះដល់ខែ ១២ ឆ្នាំ២០០៩ មានការបោះឆ្នោតមួយកើតឡើងក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ពីចៅក្រមតុលាការក្រុងអូកឡឹនដ៍។ ពេលនោះពន្លឺយុត្តិធម៌បានផុសចេញជាក់ស្តែង គឺខាងដើមចោទទទួលបានជោគជ័យ មានសិទ្ធិការពារថែរក្សាវត្ត សំរាប់ប្រគេនព្រះសង្ឃគង់នៅជាស្រែបុណ្យនៃពុទ្ធបរិស័ទគ្រប់ចតុទិស។

យោងតាមប្រសាសន៍របស់លោក*អ៊ិន សួន* អនុប្រធានគណៈកម្មការវត្តបានបញ្ជាក់ថា៖ *តុលាការសំ



ព្រះតេជគុណ**ធម្មសារ សម សុន** ព្រះសង្ឃព្រមទាំងលោក **អ៊ិន សួន** និងពុទ្ធបរិស័ទវត្តអូកឡឹនដ៍ ទទួលព្រះសរីរិកធាតុពី **ព្រះមហា ឥន្ទេ** វត្តសិរីលង្កា នៅបឺឃ្លី (Berkeley)

រេចជាស្ថាពរឱ្យព្រះសង្ឃ គណៈកម្មការ និងពុទ្ធបរិស័ទមានសិទ្ធិពេញលេញ ចូលទៅរៀបចំវត្តឡើងវិញ នៅថ្ងៃទី១២ ខែ១ឆ្នាំ២០១០។* ដើម្បីបំពេញបំណងនឹងសមិទ្ធិផលដែលទទួលបានពីការខិតខំប្រឹងប្រែង តស៊ូ ពុះពារគ្រប់ឧបសគ្គរហូតដល់បានជោគជ័យ តាមផ្លូវច្បាប់នោះ ព្រះសង្ឃ គណៈកម្មការវត្ត និងពុទ្ធបរិស័ទ បានមូលមតិគ្នាធ្វើពិធីបុណ្យអបអរសាទរចូលនៅវត្តខ្មែរអូកឡឹនដ៍ តាមប្រពៃណីព្រះពុទ្ធសាសនា ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី១២-១៣-១៤ ខែ មីនា ឆ្នាំ២០១០ កន្លងទៅហើយនេះ ដែលមានព្រះសង្ឃពីវត្តនានាចំនួន២០អង្គ ព្រមទាំងពុទ្ធបរិស័ទអញ្ជើញចូលរួមយ៉ាងច្រើនកុះករ ហើយនឹងមានក្រុមរបាំអប្សរាក្រុងសាន់ហូស្សេ រាំជូនពរផងដែរ។

នៅក្នុងពិធីនោះដែរ លោក*មួន ច័ន្ទតារា* ប្រធានគណៈកម្មការវត្ត បានឡើងថ្លែងអំណរគុណភ្ញៀវកិត្តិ



គណៈកម្មការវត្តខ្មែរអូកឡឹនដ៍ និងលោក Sternfeld David

យសជិតឆ្ងាយទាំងអស់ ដែលបានជួយឧបត្ថម្ភគាំទ្រវត្តទាំងផ្នែកថវិកា និងស្មារតី។លោកបានបញ្ជាក់បន្ថែមថា *ក្នុងឆ្នាំ២០១០នេះ វត្តខ្មែរអូកឡឹនដ៍នឹងបើកបង្រៀនអក្សរខ្មែរ សិល្បៈ និងការរៀនចូលសញ្ជាតិជាដើម។*

លោក*អ៊ិន សួន* បានឱ្យដឹងបន្ថែមទៀតថា លោកមានការសោកស្តាយនូវអ្វីដែលបានកើតឡើង នៅក្នុងវត្តខ្មែរអូកឡឹនដ៍រយៈពេលកន្លងមកនោះ គឺក្រុមគណៈកម្មការរបស់លោក និងសមាជិក-កា គ្មានចេតនាក្នុងការប្តឹងផ្តល់ជាមួយនឹងមន្ត្រីសង្ឃខ្មែរអន្តរជាតិទេដោយយល់ថា យើងជាខ្មែរដូចគ្នា ត្រូវការសាមគ្គីគ្នា រួបរួមគ្នា តែមន្ត្រីសង្ឃខ្មែរអន្តរជាតិមិនព្រមសំរបសំរួល។ ដើម្បីទប់ស្កាត់បញ្ហាទាំងនេះកុំឱ្យកើតមានតទៅទៀតគណៈកម្មការវត្ត និងពុទ្ធបរិស័ទរកមេធាវីមួយរូបសំរាប់ចង្អុលបង្ហាញពីផ្លូវច្បាប់ព្រមទាំងមានផែនការនិមន្តព្រះសង្ឃដែលមានពុទ្ធិនិស្ស័យ ស្មោះត្រង់នឹងសង្គម ក្នុងការដឹកនាំព្រះពុទ្ធសាសនា។លោកបានបន្តទៀតថា វត្តខ្មែរអូកឡឹនដ៍នឹងបើកបង្រៀនអក្សរខ្មែរ ភ្លេងប្រពៃណីការអប់រំសីលធម៌និងបង្រៀនកុំព្យូទ័រដល់ចាស់ៗជាដើម។

លោកសូមអំពាវនាវដល់ពុទ្ធបរិស័ទ ដែលពុំទាន់យល់ច្បាស់ពីបញ្ហាវត្តខ្មែរអូកឡឹនដ៍នោះ សូមមេត្តាពិចារណានឹងសំរួលអារម្មណ៍ឡើងវិញដើម្បីរួបរួមកំលាំងគ្នាកសាងវិស័យព្រះពុទ្ធសាសនានិងសង្គមខ្មែរយើងឱ្យមានភាពរីកចំរើនរុងរឿងនៅបរទេស៕

ដោយ ស៊ឹម សុរិយា

**(តមកពីទំព័រទី៨)** តំណាងឲ្យ ព្រះចូលាមុនីចេតិយ សំរាប់បញ្ចុះព្រះកេសា និងព្រះចង្កូមកែវនៃព្រះបរមគ្រូ។

•ថ្ងៃទីបី ជាថ្ងៃឡើងសក្តិ ចាប់ផ្តើមចូលសករាជថ្មី ពុទ្ធបរិស័ទតែងតែនិមន្តព្រះសង្ឃបង្សុកូល ឆ្លងភ្នំខ្សាច់, ស្រង់ទឹកព្រះពុទ្ធបដិមាព្រមទាំងមានការងូតទឹកជូនមាតាបិតាដើម្បីសូមសុខចំរើនសំរាប់ពេលបច្ចុប្បន្ននិងទៅអនាគត។

រយៈកាលបីថ្ងៃនៃបុណ្យចូលឆ្នាំនេះដែរ ពុទ្ធបរិស័ទរៀបចំចង្ហាន់បិណ្ឌបាត្រ យកទៅប្រគេនព្រះសង្ឃតាមវត្តអារាមនានា ដើម្បីឧទ្ទិសកុសលជូនមាតាបិតា ញាតិកាទាំង៧សន្តានផងដែរ។ ជាពិសេសនៅតាមវត្តអារាម និងភូមិស្រុកនីមួយៗមានការប្រគុំតូរ្យតន្ត្រីនិងនាំគ្នាលេងល្បែងប្រជាប្រិយដូចជា បោះអង្គុញ, ចោលឈូង, ទាញព្រ័ត្រទៅតាមប្រពៃណីទំនៀមទម្លាប់ខ្មែរយើង។

ប្រកាសសង្ក្រាន្តឆ្នាំថ្មី គឺឆ្នាំខាល ប្រព្រឹត្តទៅនៅថ្ងៃពុធ ១កើត ខែពិសាខ ព.ស២៥៥៤ ត្រូវនឹងថ្ងៃ១៤មេសា គ.ស២០១០ វេលាម៉ោង៧និង៣៦នាទីព្រឹក។ ទេពធីតាព្រះនាម **មណ្ឌាទេវី** បុត្រីទី៤នៃកបិលមហាព្រហ្ម ទ្រង់គង់លើខ្នងសត្វលា ជាពាហនៈ សោយទឹកដោះស្រស់ ដៃស្តាំទ្រង់ម្ជុល ដៃឆ្វេងទ្រង់ឈើច្រត់។

បុណ្យចូលឆ្នាំខ្មែរយើងមានគោលបំណងច្បាស់លាស់មួយ ដែលគ្មានការផ្លាស់ប្តូរតាំងពីបុរាណរហូតមកដល់សព្វថ្ងៃនេះគឺ៖ ការកសាងជីវភាពផ្ទាល់ខ្លួន និងសង្គមថ្មី ព្រមទាំងបំភ្លេចនូវរឿងរ៉ាវអពមង្គលឆ្នាំចាស់ចោល, អបអរចំពោះធម្មជាតិថ្មី ផលិតផលថ្មី,សំដែងកតញ្ញូតាធម៌ចំពោះបុព្វការីជនមានមាតាបិតា ជីដូនជីតា គ្រូបាធ្យាយ និងគោរពដល់ដួងវិញ្ញាណក្ខន្ធនៃវីរសមណៈ វីរបុរសគ្រប់ជំនាន់ ព្រមទាំងទំនុកបំរុងនិងថែរក្សាវិស័យព្រះពុទ្ធសាសនាឲ្យបានគង់វង្សគ្រប់៥០០០ព្រះវស្សា។ជាពិសេសបណ្តុះបណ្តាលព្រហ្មវិហារធម៌ សាមគ្គីធម៌ក្នុងដួងចិត្តខ្មែរយើងគ្រប់ៗរូប ទោះបីរស់នៅទីណាក៏ដោយ។

ក្នុងឱកាសសង្ក្រាន្ត៣ថ្ងៃនេះ សូមពុទ្ធបរិស័ទទាំងអស់រៀបចំពលិការគ្រឿងសក្ការបូជា អុជប្រទីបធូបទៀនថ្វាយព្រះរតនត្រ័យនិងទទួលទេវតាឆ្នាំថ្មី ហើយខំលះបង់ចិត្តអាក្រក់អន្យតិរ្ថិយអប្រិយជាប់ដោយគំនុំគុំគួនព្យាបាទឈ្នានីស ដែលកើតមានក្នុងឆ្នាំចាស់ឲ្យជ្រះស្រឡះ តាំងចិត្តប្រព្រឹត្តល្អប្រកបដោយ មេត្តា ករុណា មុទិតា ឧបេក្ខា និង បញ្ញា ធ្វើបុណ្យសុន្ទរទានតាមប្រពៃណី ខំរក្សាសីល៥ឲ្យជាប់ជានិច្ច ពេលនោះទេវតាឆ្នាំថ្មីឲ្យពរសព្វសាធុការចំពោះអស់លោកអ្នកនឹងមានសិរីសួស្តី សុភមង្គល វិបុលសុខគ្រប់ប្រការ តាំងពីឆ្នាំថ្មីនេះតរៀងទៅជានិច្ចនិរន្តរ៍៕

ដោយ ស៊ឹម ចន្ទ្រា

---

**(តមកពីទំព័រទី៧)**ទាក់ទងនឹងប្រាក់កាស(បច្ច័យ)នេះដែរ នៅក្នុងទ្រឹស្តីព្រះពុទ្ធសាសនាបានចែងមកថា សព្វសត្វទាំងអស់រស់បានអាស្រ័យអាហារឬបច្ច័យទាំង៤។តែបច្ច័យទាំង៤នេះគឺបានមកប្រកបដោយធម៌ មិនមានការលួចប្លន់អ្នកដទៃខិតខំប្រឹងប្រែងស្វែងរកដោយកម្លាំងកាយចិត្តរបស់ខ្លួនយ៉ាងពិតប្រាកដស្របតាមច្បាប់សង្គមផងនោះ មិនតែប៉ុណ្ណោះព្រះពុទ្ធបានប្រៀនប្រដៅយើងថា ប្រាក់ដែលរកបានហើយត្រូវបែងចែកជា៤ចំណែកគឺសងបំណុលចាស់ក្នុងការចិញ្ចឹមមាតាបិតា,បុលបំណុលថ្មី ការចិញ្ចឹមកូនចៅឱ្យសិក្សារៀនសូត្រ,បោះក្នុងជ្រោះជ្រៅ ការចិញ្ចឹមជីវិតប្រចាំថ្ងៃ, កប់ជាកំណប់ទ្រព្យ ការធ្វើបុណ្យទាន ជួយអ្នកក្រីក្រ ទុគ៌ត និងការកសាងសមិទ្ធិផលនានា មានសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ វត្តអារាមជាដើម។

ដូចបានអត្ថាធិប្បាយមកខាងលើ ប្រាក់គឺជាកាំបិតមុខពីរ បើប្រើប្រាស់ត្រូវនឹងនាំភាពរីកចំរើន សុខសាន្តផ្តល់ឱ្យខ្លួនផ្ទាល់ និងសង្គមជាតិទាំងមូលមានការលូតលាស់រុងរឿង ហើយមនុស្សទូទៅទទួលបានសុភមង្គល គ្រប់ពេលវេលា ជាពិសេសយើងបានចូលរួមអភិវឌ្ឍសង្គមប្រកបដោយសុចរិតយុត្តិធម៌៕ ដោយ ថាច់ សុរិយា

# បុណ្យចំរើនជន្មាយុ និងគំរប់ខួប១០០ថ្ងៃ នៅវត្តខេមររង្សី ក្រុងសាន់ហូសេ



លោក បៃ សារិទ្ធក្នុងពិធីបុណ្យចំរើនជន្មាយុ នៅវត្តខេមររង្សី

នៅថ្ងៃទី ៦ ខែមីនា ឆ្នាំ២០១០ កន្លងមកនេះ អ្នកគ្រូ សុផានី បៃព្រមទាំងញាតិមិត្ត បានរៀបចំពិធីចំរើនអាយុជូនលោក បៃ សារិទ្ធ ដែលត្រូវជាស្វាមី ទៅតាមទំនៀមទម្លាប់ប្រពៃណីព្រះពុទ្ធសាសនា នៅក្នុងវត្តខេមររង្សី ទីក្រុងសាន់ស្សេ។ នៅក្នុងពិធីបុណ្យនេះដែរ ដោយមានការនិមន្តព្រះសង្ឃចំរើនព្រះបរិត្តលើករាសី ជូនលោកបៃ សារិទ្ធ និងមានវិធីរាប់បាត្រ ដារបង្សុកូលឧទ្ទិសកុសលជូនដល់ញាតិកាទាំង៧សន្តានផង។

លោក បៃ សារិទ្ធ មានស្រុកកំណើតនៅឃុំរលាផ្អៀ ស្រុករលាផ្អៀ ខេត្តកំពង់ឆ្នាំង លោកបានចូលបំរើការងាររដ្ឋចាប់តាំងពីឆ្នាំ១៩៦១រហូតដល់ឆ្នាំ១៩៧០ ក្នុងតួនាទីជាមេបញ្ជាការកងអនុសេនាធំ រក្សាព្រះមហាក្សត្រ ក្នុងសម័យសង្គមរាស្រ្តនិយម។ លុះដល់ឆ្នាំ១៩៧៤ លោកបានឃ្លាតឆ្ងាយពីស្រុកកំណើតមកបំពេញការសិក្សាផ្នែកនាយទាហានជាន់ខ្ពស់នៅលើទឹកដីសហរដ្ឋអាមេរិក។ ដោយសារស្រុកទេសធ្លាក់ក្នុងភ្លើងសង្រ្គាមមិនឈប់ឈរ ទើបលោកសំរេចចិត្តរស់នៅសហរដ្ឋអាមរិក ប្រកបដោយភាពស្រណោះអាឡោះអាល័យ និងមានទឹកចិត្តនឹកគិតដល់វាសនាស្រុកកំណើតគ្រប់ពេលវេលា។សព្វថ្ងៃនេះលោកបៃ សារិទ្ធកំពុងរស់នៅទីក្រុងសាន់ហូសេ រដ្ឋកាលីហ្វ័រនីញ៉ា។ ទោះបីមានអាយុ៧១ឆ្នាំក្តី គាត់នៅតែមានស្មារតីរឹងប៉ឹង និងទស្សនៈល្អៗ ក្នុងការចូលរួមមតិ ដើម្បីស្ថាបនាសង្គមជាតិ និងវិស័យព្រះពុទ្ធសាសនា ជាពិសេសសង្គមវត្តខេមររង្សីជាដើម ព្រមទាំងជំរុញទឹកចិត្តអ្នកស្នេហាជាតិទាំងអស់អោយមានការសាមគ្គីនិងរួបរួមគ្នាការពារអត្តសញ្ញាណជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ អក្សរសាស្រ្តរបស់ខ្លួន អោយបានគង់វង្សគ្រប់កាលៈទេសៈទាំងអស់៕



លោក ឆាយ យ៉េត និងក្រុមគ្រួសារ ព្រមទាំងពុទ្ធបរិស័ទធ្វើបុណ្យខួបគំរប់១០០ថ្ងៃ ជូនលោកយាយ មាស ស្ដើង និងលោកយាយ អ៊ុំ ឡាច

## អំពីបុណ្យគំរប់ខួប១០០ថ្ងៃ ៖

កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០១០ លោក ឆាយ យ៉េត និងអ្នកស្រីមុយ សុគន្ធ ព្រមទាំងកូនចៅ និងញាតិមិត្តទាំងអស់ បានប្រារព្ធពិធីបុណ្យខួបគំរប់ ១០០ថ្ងៃ ជូនចំពោះវិញ្ញាណក្ខ័ន្ធលោកយាយ មាស ស្ដើង និងលោកយាយ អ៊ុំ ឡាច នៅក្នុងវត្តខេមររង្សី ក្រុងសាន់ហូសេ រដ្ឋកាលីហ្វ័រញ៉ា។

កម្មវិធីបុណ្យបានប្រព្រឹត្តទៅតាមប្រពៃណី ព្រះពុទ្ធសាសនា ដោយមានធ្វើកិច្ចនមស្សការ សមាទាននិច្ចសីល រាប់បាត្រ និងវេរភត្តប្រគេនព្រះសង្ឃ ដារបង្សុកូល ឧទ្ទិសមហាកុសលនេះ ជូនចំពោះបុព្វការីជន មានមាតាបិតា និងញាតិកាទាំង៧សន្តាន ក្នុងនោះមានវិញ្ញាណក្ខ័ន្ធលោកយាយ មាស ស្ដើង និងលោកយាយ អ៊ុំ ឡាច ជាដើម។

ពិធីបុណ្យខួប១០០ថ្ងៃនេះ ពុទ្ធបរិស័ទនៅគ្រប់ទិសទីទាំងអស់ តែងតែនាំគ្នាប្រារព្ធឡើង **(តទៅទំព័រទី២៤)**

# ជីវប្រវត្តិសង្ខេប និង ការតស៊ូរបស់វីរសមណៈ ហែម ចៀវ

**ព្រះវីរសមណ ហែម ចៀវ ប្រសូតិ** ថ្ងៃអង្គារ ឆ្នាំច ពស ២៤៤០ គស ១៨៩៨**ស្រុកកំណើត** ភូមិអូរកូនទេញ(កោណ្ឌិញ្ញ) សង្កាត់ដំបូកមានលក្សណ៍ ស្រុកឧដ្តុង ខេត្តកំពង់ស្ពឺ **ឪពុក** ហែម(មេស្រុកដំបូកមានលក្សណ៍) **ម្តាយ** ទីវ **បងប្អូន** ៥នាក់គឺ ហែម លី, ហែម ចៀវ, ហែម ហួត, នាងហែម សុច, ហែម សាយ។

**កុមារភាព៖** កាលនៅពីកុមារ លោកបានស្គាល់នូវសេចក្តីលំបាកគ្រប់បែបយ៉ាង ដូចជាកូនកសិករក្រីក្រទូទៅដែរ។រហូតដល់អាយុ១២ឆ្នាំទើបមេស្រុកហែមជាឪពុកនាំយកទៅប្រគេនព្រះសង្ឃសត្ថាជួន **ណាត វត្តឧណ្ណាលោមក្រុងភ្នំពេញ** ដោយហេតុមេស្រុក ហែម និងព្រះគ្រូ សង្ឃសត្ថាជាមិត្តភក្តិនឹងគ្នាយ៉ាងជិតស្និទ្ធ។

កុមារ **ហែម ចៀវ** ជាក្មេងមានសីលធម៌ល្អប្លែកជាងក្មេងដទៃៗ ទៀតមានថ្វីមាត់ចេះពាក្យច្បាស់លាស់មានសន្តាប់ធ្នាប់សមរម្យគួរអោយអ្នកផងពេញចិត្ត។

កុមារនេះ មានការព្យាយាមខ្ជាប់ខ្ជួនល្អណាស់ បានរៀនអក្សរសាស្ត្រ ក្នុងសំណាក់ព្រះគ្រូសង្ឃសត្ថា តាំងអំពីដំបូង រហូតទាល់តែមើលបាន សរសេរអក្សរកើតដោយបរិបូណ៌។កុមារ **ហែម ចៀវ** បាននៅសិក្សាអប់រំក្នុងសំណាក់ព្រះគ្រូសង្ឃសត្ថា **ជួន ណាត** អស់យូរឆ្នាំ ដោយបានដើរស្ពាយយាម ព្រះគ្រូសង្ឃសត្ថា ដែលត្រូវនិមន្តទៅទេសនា ក្នុងស្រុក ខេត្ត ឯទៀតៗ ជាញឹកញយ។ កុមារ **ហែម ចៀវ** បានស្តាប់ធម៌ទេសនារបស់ព្រះគ្រូសង្ឃសត្ថាអស់ច្រើនឆ្នាំទើបជាហេតុនាំឲ្យកុមារចៀវមានសេចក្តីឆ្លៀវឆ្លាសយល់ហេតុផលក្នុងផ្លូវលោកផ្លូវធម៌ជាច្រើនយ៉ាងណាស់។ ជាកុមារមានសំដីវោហារព្រោកប្រាជ្ញពូកែជាងកុមារឯទៀតៗទាំងអស់។ កន្លែងដែលកុមារស្នាក់សិក្សា គឺស្ថិតនៅខាងក្រោយមហាកុដិសព្វថ្ងៃនេះ ។ កុមារ **ហែម ចៀវ** ព្យាយាមរៀនសូត្រឥតធ្វេសប្រហែសរវីខ្វិលច្រអូសទេ។កុមារខំរៀនមិនថាយប់មិនថាថ្ងៃ ព្រោះលោកចាំបណ្តាំបិតា ក្នុងកាលដែលឪពុកនាំយកទៅទុកក្នុងសំនាក់នៃព្រះគ្រូសង្ឃសត្ថាថា៖



ព្រះឆាយាល័ក្ខណ៍ព្រះវីរសមណៈ ហែម ចៀវ

*ចៀវកូនប្រុសសំលាញ់ឪពុកៗគ្មានអ្វីចែកអោយកូនទេ គឺមានតែវិជ្ជានេះហើយដែលឯងអាចយឹតយោងត្រកូលសារយើងអោយខ្ពង់ខ្ពស់បាន។ មនុស្សល្ងង់គេមើលងាយណាស់កូន! បើកូនចេះឪពុកក៏ចេះដែរ! កូននៅភ្នំពេញខំរៀនឡើង! កុំឈ្លោះប្រកែកគ្នាណា! ខុសត្រូវម្តេចម្តាត្រូវចេះអត់ធ្មត់ទើបប្រសើរ ព្រោះយើងជាកូនកំសត់ដើរស្វែងរកវិជ្ជាដូចគ្នា។ ដូច្នេះ ត្រូវចេះស្រលាញ់គ្នាទើបអ្នកផងសរសើរ ចូរកូនចាំសុភាសិតបុរាណមួយឃ្លាថា «នៅផ្ទះម្តាយទីទៃ ទៅព្រៃម្តាយជាមួយ» ។*

លោកគ្រូព្រះសង្ឃសត្ថាអង្គនេះ ជាអ្នកប្រាជ្ញជ្រៅជ្រះ បានជាអញនាំកូនឯងមកឱ្យនៅនឹងលោកត្រូវកូនឯងខំរៀនសូត្រយកចិត្តទុកដាក់អោយមែនទែន។

- បាទលោកឪពុក កូននឹងគោរពតាមសំដីពុកលុះថ្ងៃស្លាប់! សូមពុកកុំព្រួយបារម្ភ.........(**តទៅទំព័រទី១៨**)

(**តមកពីទំព័រទី១៧**) អោយសោះ!

- ល្អហើយកូនប្រុសឪពុក!ឯងជាតំណក់ឈាមរបស់អញហើយ អញសង្ឃឹមលើឯងគ្រប់ដប់!
- ពាក្យនេះធ្វើអោយកុមារចៀវចងចាំទុកក្នុងបេះដូងឥតមានថ្ងៃភ្លេច។ កុមារស្រលាញ់គោរពតាមឪវាទមាតាបិតាណាស់ មិនដែលធ្វើអោយអ្នកមានគុណព្រួយចិត្តម្តងណាឡើយ។

**• សាងផ្នួស**

ក្នុងវ័យ១៦ឆ្នាំក៏ចូលមកដល់លោកមេស្រុកហែមនិងភរិយាបានជំនុំគ្នា អំពីការបំបួសកូនជាសាមណេរ ហើយមូលមតិថា ត្រូវបំបួសនៅវត្ត **ឧណ្ណាលោម** ហើយអោយគង់សំណាក់សិក្សាបរិបត្តិធម៌នៅវត្តឧណ្ណាលោមដដែល។ លុះពេលបួសរួចហើយសាមណេរចៀវទន្ទេញមេសូត្រ (មូលវេយ្យាករណ៍បាលី)ចាំយ៉ាងស្ទាត់ជំនាញថ្ងៃខែចេះតែកន្លងជាលំដាប់... សាមណេរ **ហែម ចៀវ** អាយុបាន២០ឆ្នាំ ក៏បំពេញឧបសម្បទា ជាភិក្ខុភាវៈក្នុងពុទ្ធសីមានៅ **វត្តលង្កា** ដែលមានព្រះមហាវិមលធម្មថោង (ចាងហ្វាងសាលាបាលីជាន់ខ្ពស់មុនដំបូង) ជាឧបជ្ឈាយ៍ មានព្រះគ្រូបវរវិជ្ជា **ល្វី ឯម** និងព្រះគ្រូសង្ឃសត្ថា **ជួន ណាត** ជាគ្រូសូត្រ។ នៅពេលបំពេញជាភិក្ខុហើយ លោកក៏បានប្រឡងចូលរៀនសាលាបាលីជាន់ខ្ពស់ជាប់ដូចចិត្តប្រាថ្នា។ ក្នុងការសិក្សាចំនួន៧ឆ្នាំនៅសាលាបាលីជាន់ខ្ពស់ ធ្វើអោយលោកចេះដឹងផ្លូវលោក ផ្លូវធម៌ល្អមប្រើការបានដោយពេញបរិបូណ៌ ក្នុងផ្លូវព្រះពុទ្ធសាសនា។ លោកជាសិស្សសំនប់មួយរូប នៃព្រះគ្រូសង្ឃសត្ថាជួន **ណាត** ដែលលោកស្រលាញ់ជាងគេដោយភិក្ខុ**ហែម ចៀវ** ជាបព្វជិតឈ្លាសវៃរហ័សរហួនគួរសមទៅតាមឋានៈជាមនុស្សដូចគ្នា លុះគំរប់ឆ្នាំទី៧លោកបានប្រឡងយកសញ្ញាប័ត្រឌីប្លូមសាលាបាលីជាន់ខ្ពស់ជាប់លេខ៦ខាងភាសាបាលីដែលសម័យនោះ ខ្មែរយើងកំពុងរាប់អានណាស់។ នៅពេលប្រឡងចេញពីសាលាបាលីហើយ ក្នុងឆ្នាំ១៩២៧ កាលណោះលោករ៉េស៊្យូមជាតិបារាំង ធ្វើជារ៉េស៊ីដង់ខេត្តកំពត បានពឹងលើលោកមេគណវត្តអង្គសុរភីហៅកន្លោរ ស្រុកកំពង់ត្រាច អោយជួយរកលោកសង្ឃមួយអង្គ ដែលមានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ក្នុងកាលនោះលោកគ្រូមេគណវត្តកន្លោរ និមន្តមកឯវត្តឧណ្ណាលោមក្រុងភ្នំពេញមកពឹងព្រះគ្រូសង្ឃសត្ថា **ជួន ណាត** សូមនិមន្តលោកមួយអង្គដែលមានសញ្ញាប័ត្រឌីប្លូមសាលាបាលីជាន់ខ្ពស់ ទៅបង្រៀនអក្សរសាស្ត្រខ្មែរនៅខេត្តកំពត ដោយហេតុលោករ៉េស៊ីដង់រ៉េស៊្យូម ខេត្តកំពតបង្កើតអង្គការសិក្សាអក្សរសាស្ត្រខ្មែរ អោយមានរបៀបត្រឹមត្រូវឡើង។

កាលនោះព្រះគ្រូសង្ឃសត្ថា បានចាត់លោកអាចារ្យ **ហែម ចៀវ** អោយទៅបង្រៀនអក្សរសាស្ត្រជាតិឯខេត្តកំពតយកវត្តក្រាំងដូង ស្រុកបន្ទាយមាសនិងវត្តកន្លោរស្រុកកំពង់ត្រាចជាមជ្ឈមណ្ឌល។ គ្រូអាចារ្យ **ហែម ចៀវ** បានទៅនៅបង្រៀនអក្សរសាស្ត្រជាតិក្នុងខេត្តកំពតអស់៦ឆ្នាំ គឺតាំងពីឆ្នាំ១៩២៧ ដល់១៩៣២ ទើបត្រលប់មកនៅភ្នំពេញវិញរួចបានប្រឡងជាប់ជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ក្នុងឆ្នាំនោះឯង។ ក្រៅពីម៉ោងបង្រៀនសិស្សលោកអាចារ្យតែងនិមន្តទៅទេសនាជាញឹកញយ។ ទេសន៍កន្លែងណាក៏ដូចកន្លែងណាដែរ លោកច្រើនតែយកពុទ្ធភាសិតថា «វិរិយេន ទុក្ខមច្ចេតិ »ហើយនិង «អត្តា ហិ អត្តនោ នាថោ » មកអធិប្បាយពន្យល់លើកឧទាហរណ៍ដើម្បីអោយពុទ្ធបរិស័ទងាយស្តាប់បាន ។ លក្ខណខ្លះដែលគួរដឹងលោកគ្រូអាចារ្យ **ហែម ចៀវ** មានសំលេងធំក្រអួន មានទឹកដមគួរអោយចង់ស្តាប់ហើយស្តាប់ទៀត មានវោហាក្បោះក្បាយរអិលទៅមុខជាដរាប......**(តទៅលេខក្រោយ)**

# ខ្មែរក្រោមម្នាក់ ត្រូវកាត់ទោសឲ្យជាប់គុក២ឆ្នាំ ពីបទបំផ្លើសការពិត

តុលាការវៀតណាម ក្នុងទឹកដីខ្មែរកម្ពុជាក្រោម កាលពីថ្ងៃ១៩មីនានេះ បានកាត់ទោសប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមម្នាក់លោកហ្វិន បា ឲ្យជាប់គុក២ឆ្នាំក្រោមបទចោទថា បាននិយាយប្រាប់វិទ្យុអាស៊ីសេរីបំផ្លើសពីការពិត ប៉ះពាល់កិត្តិយសកម្មាភិបាលវៀតណាម ក្នុងរឿងតវ៉ាទាមទារដីធ្លី និងបានដឹកនាំការតវ៉ាដីធ្លីកន្លងមក។

ប្រភពបានឲ្យដឹងថាលោក ហ្វិន បាកំពុងតែជាប់ឃុំខ្លួននៅក្នុងគុកនៅខេត្តឃ្លាំង ដោយគេមិនអនុញ្ញាតឲ្យក្រុមគ្រួសារចូលសួរសុខទុក្ខទេ។

ស្ត្រីខ្មែរកម្ពុជាក្រោមម្នាក់ នៅក្នុងស្រុកបឹងសន្សាខេត្តឃ្លាំង ប្រទេសវៀតណាម ទឹកដីខ្មែរកម្ពុជាក្រោម ដែលធ្លាប់បានចូលរួមតវ៉ាទាមទារដីធ្លីកន្លងមក ជាមួយលោក ហ្វិន បា បានថ្លែងប្រាប់វិទ្យុអាស៊ីសេរី តាមទូរស័ព្ទមកថា៖ *«ហ្វិន បា គេកាត់ទោសពីម្សិលមិញ (១៩ មីនា) រួចហើយ។ ខ្ញុំធ្លាប់ដើរទៅប្ដឹងរឿងទឹកដីជាមួយ ហ្វិន បា ជាមិត្តភក្តិស្គាល់គ្នាទៅជួប»*។

ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមម្នាក់ទៀតនៅខេត្តអានយ៉ាង ប្រទេសវៀតណាម ទឹកដីខ្មែរកម្ពុជាក្រោម បានថ្លែងថា ៖ *«សោកស្ដាយដែរ ព្រោះថា យើងខំធ្វើអស់ដើមអស់ចុងមួយគំនរ ហើយគេយកអស់អ៊ីចឹងធ្វើម៉េចទៅ? ទាមទារឲ្យដោះលែងវិញ បើគេមិនឲ្យជួបសោះអីងបើសិនជាគេធ្វើបាបក៏គ្មាននរណាដឹងដែរ»*

យោងតាមសេចក្ដីប្រកាសព័ត៌មានពីសហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំនៅក្នុងប្រទេសកម្ពុជាដែលវិទ្យុអាស៊ីសេរីទទួលបាននៅថ្ងៃសៅរ៍នេះ លោក ហ្វិន បា បានរងការចាប់ខ្លួនដោយនគរបាលវៀតណាម កាលពីខែឧសភា ឆ្នាំ២០០៩កន្លងទៅ ដាក់ក្នុងពន្ធនាគារខេត្តឃ្លាំង ដោយបានបង្អត់អាហារកាត់សក់បង្អាប់កិត្តិយសរហូតដល់តុលាការបើកការកាត់ទោសកាលពីថ្ងៃ ទី១៩ ខែមីនាកន្លងទៅថ្មីៗនេះ ក្រោមមាត្រាទី ១០៤ និងមាត្រាទី២៥០នៃច្បាប់រដ្ឋធម្មនុញ្ញប្រទេសវៀតណាម។



លោក វិន បា ក្នុងសវនាការ បក្សទោលកុម្មុយនិស្តយួន

ព្រះភិក្ខុសង្ឃព្រះនាម ថាច់ សុវណ្ណារ៉ា ជាអ្នកនាំពាក្យសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពនៅក្នុងប្រទេសកម្ពុជាបានមានថេរដីកាថា៖ *«អយុត្តិធម៌បំផុតចំពោះលោក ហ្វិន បា ហ្នឹងឯង។ រដ្ឋាភិបាលយួនបានគំរាមកំហែង រំលោភសិទ្ធិសេរីភាពរបស់លោក ហ្វិន បា ព្រោះលោក ហ្វិន បា មិនធ្វើអីខុសទេ គ្រាន់តែទាមទារដីធ្លីរបស់លោកប៉ុណ្ណោះដែលរដ្ឋាភិបាលយួនអូសយកដល់ពេលលោកធ្វើទៅបានក៏ចេញដីកាមកចាប់លោកយកទៅដាក់ពន្ធនាគារ កាត់ទោសលោកថា លោកធ្វើបះបោរអំពីនយោបាយ»*។

ជាមួយគ្នានេះព្រះសង្ឃ យឿង ស៊ិន ជាប្រធានសហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោម នៅក្នុងប្រទេសកម្ពុជា បានមានព្រះថេរដីកាជាមួយពាក្យធ្ងន់ៗថា ៖ *«និយាយពីវៀតណាម វាអត់ត្រូវទេ និយាយយួន។ អាយួនគំនិតវាតែប៉ុណ្ណឹង ចរិតយួន។ យើងថា វៀតណាម វាមិននេះទេ បើថារឿងយួន ចារិតវាតែប៉ុណ្ណឹង»*។

វិទ្យុអាស៊ីសេរី មិនអាចទាក់ទងមន្ត្រីនៃស្ថានទូតវៀតណាម នៅក្នុងប្រទេសកម្ពុជាបានទេ នៅថ្ងៃសៅរ៍ ជាថ្ងៃឈប់សម្រាក។

លោក ហ្វិន បា ធ្លាប់បានដឹកនាំគ្រួសារខ្មែរកម្ពុជាក្រោមជាច្រើននាក់កាលពី ឆ្នាំ២០០១ រហូតដល់ឆ្នាំ ២០០៩កន្លងទៅ ដើម្បីទាមទារដីធ្លី**(តទៅទំព័រទី២៤)**

# រដ្ឋាភិបាលមិនពេញចិត្តនឹងរបាយការណ៍សិទ្ធិមនុស្សរបស់អាមេរិក



លោកស្រី Hillary Clinton រដ្ឋមន្ត្រីការបរទេសអាមេរិក

មន្ត្រីរដ្ឋាភិបាលកម្ពុជាបានបញ្ចេញប្រតិកម្មមិនសប្បាយចិត្តតបទៅនឹងរបាយការណ៍ ស្តីពីសិទ្ធិមនុស្សរបស់សហរដ្ឋអាមេរិក ដែលបានបង្ហាញពីចំណុចអវិជ្ជមានមួយចំនួនទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស នៅកម្ពុជា។ របាយការណ៍ប្រចាំឆ្នាំ២០០៩ ដែលចេញផ្សាយដោយរដ្ឋាភិបាលទីក្រុងវ៉ាស៊ីនតោននៅចុងសប្តាហ៍នេះបានកត់សម្គាល់អំពីការរឹតត្បិតសេរីភាពបញ្ចេញមតិការបណ្តេញពលរដ្ឋចេញពីផ្ទះសម្បែង និងការចាប់បញ្ជូនជនជាតិភាគតិចអ៊ុយហ្គួរត្រឡប់ទៅស្រុកចិនវិញជាដើម។

មន្ត្រីរដ្ឋាភិបាលជាច្រើននាក់បានបញ្ចេញប្រតិកម្មជាបន្តបន្ទាប់ ដោយសម្តែងការមិនសប្បាយចិត្តចំពោះរបាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាប្រចាំឆ្នាំ២០០៩របស់សហរដ្ឋអាមេរិក។របាយការណ៍ដែលទើបតែត្រូវបានគេផ្សព្វផ្សាយនៅចុងសប្តាហ៍នេះបានកត់សម្គាល់អំពីទិដ្ឋភាពពីរបែប ស្តីពីវិស័យសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។ ទិដ្ឋភាពទី១ របាយការណ៍នេះបានលើកឡើងអំពីចំណុចវិជ្ជមានមួយចំនួន ដែលប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងធ្វើឲ្យមានការគោរពសិទ្ធិមនុស្ស។ ចំណុចវិជ្ជមានទាំងនោះរួមមានការដាក់ឲ្យអនុវត្តច្បាប់ស្តីពីការការពារសិទ្ធិជនពិការ ឪ្យបានល្អប្រសើរនូវសិទ្ធិជនរងគ្រោះដោយសារការជួញដូរមនុស្ស និងការថយចុះនៃអំពើសម្លាប់មនុស្សតាមទំនើងចិត្ត។

ការថយចុះនេះ បានស្តែងឡើងតាមរយៈការប្រកាន់វិន័យបានល្អជាងមុន របស់មន្ត្រីថ្នាក់ដឹកនាំ នៃកងកម្លាំងរក្សាសន្តិសុខ ដោយសារការខិតខំរបស់រដ្ឋាភិបាលក្នុងការបណ្តុះបណ្តាលពួកគេបានល្អ។ យ៉ាងណាក៏ដោយ ការរំលោភសិទ្ធិមនុស្សនៅកម្ពុជាមិនទាន់ចប់ទេ។សេរីភាពបញ្ចេញមតិតាមរយៈសារព័ត៌មានត្រូវបានគេរឹតត្បិត ដោយសារការប្តឹងផ្តល់ក្រោមបទចោទប្រកាន់អំពីបរិហារកេរ្តិ៍ និង ការផ្សព្វផ្សាយព័ត៌មានមិនពិត ការចាប់បញ្ជូនជនជាតិភាគតិចអ៊ុយហ្គួរចំនួន២០នាក់ ដែលប៉ុនប៉ងសុំសិទ្ធិជ្រកកោននយោបាយឲ្យត្រឡប់ទៅប្រទេសចិនវិញកាលពីចុងឆ្នាំ២០០៩ ក៏ស្ថិតក្នុងបញ្ជីនៃការរំលោភសិទ្ធិមនុស្ស របស់ទីក្រុងវ៉ាស៊ីនតោនដែរ។ ក្រៅពីនោះរដ្ឋាភិបាលកម្ពុជានៅតែបន្តនយោបាយបណ្តេញពលរដ្ឋក្រីក្រចេញពីភូមិដ្ឋាន របស់ពួកគេ។ ប៉ុន្តែចំណុចដែលបានលើកឡើងក្នុងរបាយការណ៍ទាំងអស់នេះត្រូវបានមន្ត្រីរដ្ឋាភិបាលបដិសេធ។ មានមន្ត្រីរដ្ឋាភិបាលយ៉ាងហោចណាស់ក៏៣រូបដែរ ដែលបានបញ្ចេញប្រតិកម្មតបទៅនឹងរបាយការណ៍នេះគឺលោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស លោក ឱម យ៉ិនទៀង ប្រធានគណៈកម្មការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល និងលោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី។

សម្រាប់មន្ត្រីរដ្ឋាភិបាល ការប្តឹងអ្នកកាសែត ឬការចាប់បញ្ជូនជនជាតិអ៊ុយហ្គួរត្រឡប់ទៅស្រុកវិញមិនមែនជាការរំលោភសិទ្ធិមនុស្សទេ ប៉ុន្តែគឺជាការអនុវត្តន៍ច្បាប់របស់ប្រទេសតែប៉ុណ្ណោះ។ មន្ត្រីរដ្ឋាភិបាលទាំងនោះ បានស្តីបន្ទោសអ្នកធ្វើរបាយការណ៍ថាបានមើលរំលងបញ្ហាទាំងនេះ។ យ៉ាងណាក៏ដោយ របាយការណ៍នេះត្រូវបានទទួលស្គាល់ដោយអង្គការសង្គមស៊ីវិលនៅកម្ពុជា៕

ប្រភព AFP

# ខួបឆ្នាំទី៤០ នៃរដ្ឋប្រហារទម្លាក់សម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០នេះ ជាថ្ងៃខួបទី៤០នៃការទម្លាក់អតីតសម្តេចព្រះប្រមុខរដ្ឋ នរោត្តមសីហនុ ពីតំណែង ដោយសំឡេងសមាជិកសភាតំណាងរាស្ត្រចំនួន ៩២ ទល់នឹង ០។

អ្នកនយោបាយខ្លះបានចោទថា ភ្នាក់ងារស៊ើបការណ៍សម្ងាត់អាមេរិកាំងសេអ៊ីអា មានចំណែកក្នុងការទម្លាក់ព្រះអង្គ។ក្រុមខ្លះថា ថ្ងៃនោះហើយជាប្រភពដើមនាំទៅរកការបញ្ឆេះភ្លើងសង្គ្រាម មានការទម្លាក់គ្រាប់បែកពីយន្តហោះអាមេរិកាំងជាដើម ហើយ និង ផ្តល់កំណើតដល់របបប្រល័យពូជសាសន៍ខ្មែរក្រហម។

ពលរដ្ឋខ្មែរជាច្រើននៅចងចាំព្រឹត្តិការណ៍កាលពី៤០ឆ្នាំមុនដែលកម្ពុជាបានចូលក្នុងភ្លើងសង្គ្រាមបង្ហូរឈាមរហូតបណ្តាលឲ្យពលរដ្ឋខ្មែរបាត់បង់ជីវិតអស់ជាច្រើនសែននាក់។ ប្រវត្តិវិទូបានកត់ត្រាទុកនូវភស្តុតាងជាច្រើន ដែលមនុស្សជាច្រើនបានដឹងច្បាស់ ហើយបញ្ជាក់ដោយអ្នកនយោបាយបរទេសផងនោះថាសង្គ្រាមនៅកម្ពុជា មានទ័ពព្រៃបរទេសរួមដៃច្បាំងជាមួយទ័ពព្រៃខ្មែរនៅក្នុងស្រុកពីដើម ក្រុមទីមួយហៅថាខ្មែររំដោះ ហើយមួយក្រុមទៀតហៅថា ខ្មែរក្រហម។

ពលរដ្ឋខ្មែរមួយភាគបានទម្លាក់កំហុសទាំងស្រុងទៅលើឧត្តមសេនីយ៍ លន់ នល់ ដែលទទួលអនិច្ចកម្មជាយូរឆ្នាំទៅហើយនោះ ថាជាមនុស្សក្បត់ជាតិ នាំភ្លើងសង្គ្រាមមកដុតនៅស្រុកខ្មែរ។ ពលរដ្ឋខ្មែរឯទៀតដែលបានដឹងអំពីដើមហេតុមុនពេលសង្គ្រាមចាប់ផ្តើម ពេញបន្ទុក ថា លោក លន់ នល់ បានព្យាយាមយ៉ាងទទូចសូមយាងអតីតសម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ ពីប្រទេសបារាំង ឲ្យធ្វើមាតុភូមិនិវត្តន៍ ដើម្បីស្តារស្ថានការណ៍តឹងតែងក្នុងពេលពលរដ្ឋខ្មែរធ្វើបាតុកម្ម ប្រឆាំងនឹងវត្តមានទ័ពបរទេសលើទឹកដីខ្មែរ ប៉ុន្តែព្រះអង្គមិនព្រម។

អ្នកស្រីភរិយារបស់លោក អ៊ឹង ប៊ុនហោ ដែល



អតីតសម្តេចព្រះបាទនរោត្តម សីហនុ និងវិមានឯករាជ្យខ្មែរ

ស្វាមីរបស់អ្នកស្រី នាសម័យសង្គមរាស្ត្រនិយម ជាប្រធានរដ្ឋសភាដែលជាសក្សីនៅរស់មានប្រសាសន៍ដូច្នេះនៅប្រទេសបារាំងរំឭកអំពីហេតុការណ៍នោះ ក្នុងឆ្នាំ២០០០ ៖ *«ខ្ញុំសុំធ្វើជាសាក្សី ខ្ញុំបានជួបសីហនុ មុនិក និងអ្នកហែហម»។*

*ទាំងអស់គ្នាមានព្រះអង្គម្ចាស់ សេរីមត: ឧត្តមសេនីយ៍ លន់ នល់ ព្រះអង្គម្ចាស់ គុណ តុល ក្រុមគ្រួសារទាំងអស់ ឥស្សរជនជាន់ខ្ពស់ទាំងអស់ ទាំងមាតាកុសមៈ បានទូរស័ព្ទ ហើយទូរស័ព្ទឥតឈប់ឈរដើម្បីអង្វរ សីហនុ ឲ្យត្រឡប់ទៅកម្ពុជាវិញ ព្រោះឧត្តមសេនីយ៍ លន់ នល់ និយាយថា "សម្តេចឪ យើងទាំងអស់គ្នាត្រូវការសម្តេច រាស្ត្រខ្មែរត្រូវការសម្តេច"។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះសីហនុ ស្តាប់យោបល់ម្តាយក្មេក និងប្រពន្ធ ដែលនិយាយថា សម្តេចមិនបាច់ត្រឡប់ទៅវិញទេគ្មាននរណាហ៊ានប៉ះពាល់សម្តេចទេ...»។*

ក្នុងអត្ថបទផ្សាយក្នុងកាសែត Guam Pacific Daily News នៅថ្ងៃ១៧មីនាកន្លងទៅនេះ អតីតសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោ......(តទៅទំព័រទី២៨)

# ប្រវត្តិនៃការកសាងសហភាពអឺរ៉ុប

នៅក្រោយសង្គ្រាមលោកលើកទីពីរទ្វីបអឺរ៉ុបទាំងមូលខូចខាតខ្ទេចខ្ទី សហភាពសូវៀតគិតតែពីវាតទីពង្រីកទឹកដីនិងបង្កើនឥទ្ធិពលជាហេតុធ្វើឲ្យអឺរ៉ុបខាងលិច អ្នកស្នេហាលទ្ធិប្រជាធិបតេយ្យភិតភ័យ។គឺនៅក្នុងបរិបទបែបនេះហើយ ដែល បណ្តាប្រទេសអឺរ៉ុបប្រជាធិបតេយ្យ ផ្តើមមានគំនិតចង់រួបរួមគ្នា ដើម្បីការពារខ្លួន ដើម្បីកសាងអឺរ៉ុបខាងលិចឡើងវិញនិងជាពិសេស ដើម្បីបង្កើតសន្តិភាព ចៀសវាងកុំឲ្យសង្គ្រាម ដូចសង្គ្រាមលោកលើកទីមួយ និងសង្គ្រាមលោកលើកទីពីរកើតឡើងទៀត។ បានន័យថា កាលនោះ នៅសម័យឆ្នាំ១៩៤៥ មូលហេតុសំខាន់ៗដែលជម្រុញឲ្យបណ្តាប្រទេសអឺរ៉ុបខាងលិច ចង់ប្រមូលផ្តុំគ្នាជ្រកក្រោមដំបូលតែមួយ គឺសុទ្ធសឹងជាមូលហេតុនយោបាយ។

ប៉ុន្តែនៅទីបំផុត នៅឆ្នាំ១៩៤៨ នាពេលដែលបណ្តាប្រទេសអឺរ៉ុបប្រជាធិបតេយ្យ ចំនួន១៩រួមប្រជុំគ្នានៅទីក្រុងLaHaye ប្រទេសHollande ដើម្បីជជែកគ្នា អំពីការផ្តួចផ្តើមបង្កើតអង្គការតំបន់រួមមួយស្រាប់តែបដិវាទកម្មកើតឡើង។គឺការប្រឈមមុខដាក់គ្នារវាងចក្ខុនិមិត្តពីរ។

នៅម្ខាង ប្រទេសអឺរ៉ុបមួយក្រុម ដឹកមុខដោយប្រទេសអង់គ្លេស ចង់បានត្រឹមតែសហប្រតិបត្តិការរវាងគ្នា និងចង់បានតែអង្គការអឺរ៉ុបមួយដែលមិនធ្វើឲ្យបាត់បង់សោះឡើយ អធិបតេយ្យនៃប្រទេសសមាជិកនីមួយៗ។នៅម្ខាងទៀតមានប្រទេសអឺរ៉ុបមួយចំនួនផ្សេង ដឹកនាំដោយប្រទេសបារាំង និង ប្រទេស Belgique ដែលចង់ឲ្យអភិក្រមនៃការបង្រួបបង្រួមអឺរ៉ុបនេះបោះជំហានទៅរកសហព័ន្ធមួយតាមគំរូនៃសហរដ្ឋអាមេរិកដូចអ្វីដែលអ្នកនិពន្ធបារាំងសម័យសតវត្សរ៍ទី១៩Victor Hugo ដាក់នាមឲ្យថាLes Etats-Unis d´Eu Rope



ទង់តំណាងសហភាពអឺរ៉ុប

ឬសហរដ្ឋអឺរ៉ុប។

ចក្ខុនិមិត្តទាំងពីរខុសគ្នានេះ មួយជាចក្ខុនិមិត្តអឺរ៉ុបសមាគមប្រជាជាតិ (Europedes Nations) និងមួយទៀតជាចក្ខុនិមិត្តអឺរ៉ុបសហព័ន្ធ (Europe fédérale) បន្តប្រឆាំងគ្នាមកទល់សព្វថ្ងៃ ជាង៦០ ប្លាយឆ្នាំក្រោយមក។

នៅ ឆ្នាំ១៩៥០ លោកRobert Schuman រដ្ឋមន្ត្រីការបរទេសបារាំងសម័យនោះ មានគំនិតល្អមួយនោះ គឺឈប់និយាយពីអឺរ៉ុបនយោបាយ តែនិយាយពីអឺរ៉ុបសេដ្ឋកិច្ចវិញម្តង។

លោកស្នើឲ្យដាក់ចូលជាសម្ហភាពអឺរ៉ុបធ្យូងថ្មនិងដែកថែប។ពីព្រោះ ធ្យូងថ្ម ជាថាមពលចាំបាច់សម្រាប់ឧស្សាហកម្ម និងការកសាងអឺរ៉ុបឡើងវិញ រីឯដែកថែបវិញ ជាលោហធាតុ យុទ្ធសាស្ត្រសម្រាប់ផលិតអាវុធ។នៅក្នុងស្មារតីរបស់លោកSchumanការដាក់ធ្យូងថ្មនិងដែកថែប នៅក្រោមការគ្រប់គ្រង របស់អាជ្ញាធរអឺរ៉ុបតែមួយរួមគ្នាមានគោលដៅនយោបាយ - សន្តិភាពពីព្រោះ ធ្វើបែបនេះ វត្ថុធាតុទាំងពីរមុខនេះ នឹងមិនអាចត្រូវគេយកទៅផលិតអាវុធអ្វីផ្តេសផ្តាស ដើម្បីធ្វើសង្គ្រាមបានទៀតឡើយ។ អ៊ីចឹងហើយ បានជានៅឆ្នាំ១៩៥១បណ្តាប្រទេសអឺរ៉ុបចំនួន៦គឺបារាំងអាល្លឺម៉ង់ខាងលិច Belgique,... **(តទៅទំព័រទី២៩)**

# សភាបានអនុម័តច្បាប់ស្តីពីកំណែទម្រង់ប្រព័ន្ធសុខាភិបាលរបស់លោក Barack Obama


លោក Barack Obama ប្រធានាធិបតីសហរដ្ឋអាមេរិក

គម្រោងច្បាប់ស្តីពីកំណែទម្រង់ប្រព័ន្ធសុខាភិបាល ដែលស្នើឡើងដោយលោកប្រធានាធិបតីអាមេរិក Barack Obama គឺជាប្រធានបទសំខាន់មួយនៅក្នុងចំណោមប្រធានបទសំខាន់ផ្សេងទៀតដែលលោកObamaបានសន្យានាសម័យឃោសនាបោះឆ្នោត។

ជាសរុបមានរយៈពេលជាងមួយឆ្នាំកន្លងមកហើយ ដែលព្រឹទ្ធសភានិងសភាបានជជែកដេញដោលគ្នាយ៉ាងប្រទាញប្រទង់ជុំវិញច្បាប់នេះ។ បន្ទាប់ពីព្រឹទ្ធសភាបានអនុម័តកាលពីដំណាច់ឆ្នាំ២០០៩កន្លងមក ទើបរដ្ឋសភាអនុម័តកាលពីជិតម៉ោង ១២ អធ្រាត្រ ម៉ោងនៅអាមេរិក ជាមួយនឹងសម្លេងគាំទ្រ ២១៩ ទល់នឹងសម្លេងប្រឆាំង ២១២។ តាមពិតទៅ លោក Obama ត្រូវការសម្លេងគាំទ្រតែ ២១៦ ប៉ុណ្ណោះ។

ការអូសបន្លាយ ដោយសារតែរដ្ឋសភា និងព្រឹទ្ធសភាមានជំហរផ្ទុយគ្នាលើចំណុចធំៗមួយចំនួន ជាពិសេសទាក់ទងនឹងជម្រើសថាតើរដ្ឋាភិបាលត្រូវបង្កើតក្រុមហ៊ុនធានារ៉ាប់រងសុខភាពដោយខ្លួនឯង ឬក៏គ្រាន់តែចេញលុយទិញសេវាធានារ៉ាប់រងសុខភាពឲ្យពលរដ្ឋ?និងភាពខុសគ្នាមួយទៀតគឺនៅត្រង់ប្រភពថវិកា ដើម្បីយកមកចំណាយលើការធានារ៉ាប់រងសុខភាព។

- **គម្រោងច្បាប់ត្រូវត្រលប់ទៅព្រឹទ្ធសភាជាថ្មី មុននឹងលោក Obama ប្រកាសឲ្យប្រើប្រាស់**

ជាដំបូងគម្រោងច្បាប់នឹងប្រគល់ទៅឲ្យគណៈកម្មការចំរុះមួយ ដែលបង្កើតឡើងដោយព្រឹទ្ធសភានិងរដ្ឋសភា។ ភារកិច្ចរបស់គណៈកម្មការចំរុះ គឺសំដៅកែតម្រូវ និងបំពេញបន្ថែមនូវចំណុចខុសគ្នារវាងគំពោងច្បាប់ ដែលអនុម័តដោយព្រឹទ្ធសភាកាលពីដំណាច់ខែធ្នូឆ្នាំ២០០៩ និងគំពោងច្បាប់ដែលរដ្ឋសភាទើបអនុម័តកាលពីយប់មិញ។ នៅត្រង់ចំណុចនេះ គណៈកម្មការត្រូវច្របាច់ច្បាប់ទាំងពីរបញ្ចូលគ្នាឲ្យចេញជាច្បាប់រួមមួយទទួលយកទាំងពីខាងព្រឹទ្ធសភានិងរដ្ឋសភា។

បន្ទាប់ពីពេលនោះមក ទើបលោក Obama នឹងចុះហត្ថលេខា រួចប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។ យ៉ាងណាក៏ដោយគេលែងឃើញមានឧបសគ្គធំដុំមករារាំងមិនឲ្យច្បាប់នោះចេញរួចទៀតឡើយ ពីព្រោះសម្លេងគាំទ្រភាគច្រើនលើសពី ៥០ បូក ១ ពីព្រឹទ្ធសភាគឺគ្រប់គ្រាន់។ និយាយពីថវិកាដែលត្រូវចំណាយវិញ គឺមានប្រមាណ ៩៣ម៉ឺន៨ពាន់លានដុល្លារ ក្នុងរយៈពេល១០ឆ្នាំ និងដែលអនុញ្ញាតឲ្យពលរដ្ឋអាមេរិកាំងប្រមាណពី ៣២ ទៅ ៤៧ លាននាក់ អាចទទួលបាននូវសេវាធានារ៉ាប់រងផ្នែកសុខភាពពីរដ្ឋ។នៅសហរដ្ឋអាមេរិកបច្ចុប្បន្ន មានពលរដ្ឋអាមេរិកាំង ពី៤៨ ទៅ ៥០លាននាក់ ពោលគឺជិត ១៦% នៃពលរដ្ឋសរុប គ្មានបានទទួលសេវាធានាសុខភាព ពីរដ្ឋទេ។ រីឯ ៨៤% ដែលមានសេវាធានាសុខភាព មានប្រមាណតែ ២០% ប៉ុណ្ណោះ ដែលបានទទួលការជួយទំនុកបំរុងដោយផ្ទាល់ពីរដ្ឋក្នុងនោះ មានអ្នកចូលនិវត្តន៍និងជនពិការ ដែលទទួលបានសេវាធានាសុខភាព តាមរយៈប្រព័ន្ធ « Medicare » ដែលរដ្ឋបានចំណាយពី ២០ម៉ឺនលានទៅ ៣០ម៉ឺនលានដុល្លារក្នុងមួយឆ្នាំ។បន្ទាប់មកនៅមានប្រព័ន្ធមួយ ទៀតឈ្មោះ « Medicaid » ដែលសំរាប់ជួយទំនុកបំរុងដល់អ្នកដែលមានចំណូល **(តទៅទំព័រទី២៨)**

(តមកពីទំព័រទី១៣) ពលធម្មជាតិ ដែលសត្វទាំងនោះតំណាងឲ្យជីវិត ឬធាតុដីតំណាងធញ្ញជាតិ។ ទន្ទឹមហ្នឹងនេះដែរ ការគោរពបូជាបុព្វការីជនដែលបានចែនឋានទៅ ហើយយកសពទៅកប់ព្រមទាំងបញ្ចុះគ្រឿងបរិក្ខាផ្សេងៗទៅជាមួយនោះ ប្រការនេះទាក់ទងទៅនឹងការចាប់ជាតិឡើងវិញឬភាពអមតៈនៃព្រលឹងដែលមានលក្ខណៈជាសកលតាមទំនៀមទម្លាប់ប្រពៃណីខ្មែរយើង។ ការដឹងគុណបុព្វបុរសមានអត្ថន័យខ្ពង់ខ្ពស់ណាស់ ពីព្រោះពួកគាត់ជាអ្នកត្រួសត្រាយដីព្រៃ និងការបង្កបង្កើតវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ដែលជាកេរតំណែលទុកឲ្យយើងរាល់គ្នាស្គាល់ពីតំលៃនៃអត្តសញ្ញាណជាតិ។ ការសិក្សាស្រាវជ្រាវរបស់អ្នកប្រាជ្ញខ្មែរ គឺចង់បង្ហាញនូវស្លាកស្នាមសាសនាដើម ដោយភ្ជាប់នូវបដិមាសាស្ត្រ និងវត្ថុវប្បធម៌ជាច្រើនដែលជាសមិទ្ធិផលផ្នែកបញ្ញាញាណ នាសម័យថ្មរំលីងដែលគេជួបប្រទះក្នុងស្ថានីយមួយចំនួននៃភូមិភាគឥណ្ឌូចិនយើងនេះ ដែលជាដែនដីកំណើតនៃជនជាតិខ្មែរ។

ក្នុងយុគសម័យវប្បធម៌លោហធាតុ គេក៏បានជួបប្រទះនូវការគោរពបុព្វបុរសក្រោមរូបភាពមនុស្សប្រុសនិងស្រីផងដែរ ដែលនាំឲ្យពួកគេអាចបន្តវង្សត្រកូលឬសៃស្រឡាយបាន។ គេបានរកឃើញរូបសំណាកជាច្រើនធ្វើអំពីដី ភ្លុក និងសំរឹទ្ធតំណាងឲ្យបុព្វការីជននៅតាមផ្នូរខ្មោច។

ក្នុងសម័យប្រវត្តិសាស្ត្រក្រោមឥទ្ធិពលក្លិង្គបន្តិចម្តងៗ ជំនឿទៅលើអាទិទេព ដែលជារូបសត្វឬជំនឿលើបុព្វបុរស ត្រូវប្រែទម្រង់ កែប្រែលក្ខណៈសម្បត្តិរបស់ខ្លួន ហើយបានក្លាយទៅជាអាទិទេពនៃព្រហ្មញ្ញសាសនា។ ទោះបីយ៉ាងណាក្តី ប្រជាពលរដ្ឋខ្មែរសព្វថ្ងៃនេះ បានសិក្សាស្រាវជ្រាវអំពីផលប្រយោជន៍នៃសាសនាទាំងអស់នៅលើសកលលោកនេះ ថាតើសាសនាណាមួយដែលបង្ហាញពីហេតុផលច្បាស់លាស់អាចទទួលយកបាននោះ។

យោងតាមការសិក្សាខ្មែរយើងតាំងពីបុរាណកាលមកគេតែងតែនាំគ្នាគោរពប្រតិបត្តិព្រះពុទ្ធសាសនា ព្រោះសា សនាព្រះពុទ្ធបានដឹកនាំសត្តនិករទាំងពួងឲ្យយល់ដឹងពីតំលៃជីវិតរបស់សព្វសត្វទាំងពេលបច្ចុប្បន្ន និងទៅអនាគត ដោយបញ្ជាក់ពីកម្មផលជាក់ស្តែង គឺធ្វើល្អទទួលផលល្អ ធ្វើអាក្រក់ទទួលផលអាក្រក់ជាដើម៕

*ឯកសារស្រាវជ្រាវ*

---

***(តមកពីទំព័រទី១៩)***កសិកម្មរបស់ប្រជាជនខ្មែរក្រោមដែលជាកេរពីដូនតា ហើយដែលរងការរឹបអូសយកពីសំណាក់អាជ្ញាធរវៀតណាម ចាប់តាំងពីឆ្នាំ១៩៧៨ ដើម្បីបែងចែកជាសមូហភាព៕

*ប្រភពពី RFA/03-20-2010*

---

(តមកពីទំព័រទី១៦) ដើម្បីឧទ្ទិសចំពោះអ្នកដែលស្លាប់ទៅហើយ ដោយអំណាចការធ្លាក់ចុះ ទៅក្នុងត្រៃលក្ខណ៍ធម៌ទាំង៣ប្រការ គឺអនិច្ចំ ទុក្ខំ និងអនត្តា។ធម៌ទាំង៣ប្រការនេះ ជាធម៌នៅប្រចាំក្នុងលោកមិនមានបុគ្គលណាគាត់តែងឡើងទេ ហើយក៏គ្មានអ្នកណាម្នាក់គេចផុតដែរ។

ដូច្នេះហើយ ទើបក្រុមគ្រួសារលោក ឆាយ យ៉េត ប្រារព្ធឡើងដើម្បីសំដែងនូវគុណូបការៈដ៏ធំធេងចំពោះអ្នកមានគុណរបស់ខ្លួន ព្រមទាំងបំពេញនូវ **អបមាទធម៌** គឺការមិនប្រមាទក្នុងឆាកជីវិតនិងចូលរួមថែរក្សានូវទំនៀមទម្លាប់ពីដូនតា។

សូមរំឭផងថា លោក ឆាយ យ៉េត និងគ្រួសារ តែងតែចូលរួមឧបត្ថម្ភក្នុងវិស័យសង្គមជាតិ និង ព្រះពុទ្ធសាសនាអោយបានថ្កុំថ្កើង រុងរឿង ជាពិសេសក្រុមគ្រួសាររបស់គាត់ បានលះបង់ធនធានជាច្រើនរួមចំណែកប្រគេនចង្ហាន់ដល់ព្រះសង្ឃ និងកសាងសមិទ្ធិផលនានានៅក្នុងវត្តខេមរង្សីជាដើម៕ ដោយ ស៊ឹម ចន្ទ្រា

# អាហារជួយបន្សុទ្ធបេះដូងនិងខួរក្បាល

ប្រព័ន្ធរំលាយអាហារក្នុងរាងកាយប្រឈមមុខនឹងកត្តាជាច្រើនដូចជាស្ករក្នុងឈាម សម្ពាធខ្លាញ់ក្នុងឈាម ហើយអ្នកណាដែលមានវត្តមានសារជាតុខាងលើ គឺប្រឈមមុខខ្ពស់នឹងជំងឺទឹកនោមផ្អែម និង ជំងឺបេះដូងខ្ពស់ជាងអ្នកដទៃ។



អាហារពិសេសសំរាប់ជួយបន្សុទ្ធបេះដូង និងខួរក្បាល

ដើម្បីព្យាបាលប្រព័ន្ធរំលាយអាហារបែបនេះដំបូងត្រូវផ្លាស់ប្តូរការប្រព្រឹត្តជីវិតប្រចាំថ្ងៃប្រសិនបើមិនទាន់មានឱកាសថ្មីព្យាបាលឲ្យជាសះស្បើយទេនោះដូចជា៖

- បង្កើនជាតិ ប៉ូតាស្យូម 4,7ក្រាមក្នុង1ថ្ងៃដោយបរិភោគផ្លែឈើ ប៉េងប៉ោះ ចេក ទឹកដូង បន្លែ..។
- កំណត់ជាតិអាល់កុលដោយ បុរសផឹក២ដង ,នារី១ដង ក្នុងមួយថ្ងៃ។
- កង្កើនសកម្មភាពកីឡា ដើម្បីសុខភាពដូចជាវាយសី ដើរ រត់ លោត ហែលទឹក...។
- បរិភោគអាហារមានជាតិដែកដូចជា បន្លែផ្លែឈើដោយ បន្លែ 300-400 ក្រាមនិងផ្លែឈើ 200 ក្រាមក្នុង១ថ្ងៃ។
- កំណត់ពីមធ្យោបាយនៃការប្រើស្ករ ដោយកាត់បន្ថយម្តងបន្តិចៗ ពីមធ្យោបាយនៃការប្រើស្ករដោយបន្ថយម្តងបន្តិចៗពី២០ ក្រាមមកត្រឹម 10,7 ក្រាមក្នុង១ថ្ងៃ៕

# ផ្កាឈើដុះនៅនិទាឃរដូវអាព្យាបាលរោគច្រើនយ៉ាង

ផ្ការុក្ខជាតិម្យ៉ាងដែលដុះនៅនិទាឃរដូវមានពណ៌ ផ្កាឈូកឬកុលាបព្រៃនិងមានបន្លាផងនោះត្រូវគេយកមកដាំលម្អមានកម្ពស់1-5ម៉ែត្រ។ ស្លឹកវា5-7 សន្លឹកដែលជ្រុះមកដីអាចជួយឲ្យសុខភាពរាងកាយបានល្អពិសេសអាចព្យាបាលរោគដំបៅក្រពះបាន។



ផ្កាឈើរីកក្នុងនិទាឃរដូវ

ស្លឹក: មានប្រសិទ្ធិភាពសម្រាប់ស្ត្រីក្រោយពេលឆ្លងទន្លេ និង ព្យាបាលរបួស, ព្យាបាលរោគដំបៅឬដំបៅរលួយ ស្លឹកដែលជ្រុះទម្ងន់៣០ក្រាមហាលឲ្យស្ងួតលាយជាមួយផ្កានិងទឹកឃ្មុំ ទឹកខ្មេះ ដាក់រុំពីលើដំបៅដោយកុំភ្លេចដាក់អំបិលតិចៗ ផង។ ដាក់3-4 ដងនឹងជាសះស្បើយ។គេអាចប្រើវាព្យាបាលដំបៅជើង ដៃជាដើម។

ផ្កា:ព្យាបាលរបួសត្រាំត្រែងលើសាច់ដុំដោយព្យាយាមយកទឹកផ្កា30មីល្លីលីត្រ មកលាយជាមួយទឹកក្តៅឧណ្ហៗ ដើម្បីទទួលទានឲ្យបាន១៥ថ្ងៃ។

ព្យាបាលការបញ្ចុះកម្តៅ: ប្រសិនបើមានរោគសញ្ញានៅទ្រូងមានអាការៈចង់ក្អួតឬ ឆ្អើមស្ងួតបំពង់ក សូមយកផ្កាវា៣-៩ក្រាមដាក់ទឹក100-300មីល្លីលីត្រផឹក2-3ដង បន្ទាប់ពីបរិភោគបាយ។ បើពិបាកលេបអាចដាក់ស្ករឬ ផឹកតែតាមក្រោយទៅ។

ឫស: ឫសរបស់ផ្កាឈើនេះ អាចព្យាបាលដល់ដំណើររដូវមិនទៀងទាត់ មានខ្យល់និង.(**តទៅទំព័រទី២៧**)

# FORBES : មហាសេដ្ឋីវ័យក្មេងទាំង១០របស់ពិភពលោក




យោងតាមទស្សនាវដ្ដីអាមេរិក Forbes ថាបុរសជនជាតិម៉ិចស៊ិក លោកកាឡូស ស្លីម ដែលទ្រព្យសម្បត្តិរបស់លោកមានលើសទ្រព្យសម្បត្តិរបស់លោកប៊ីលហ្គេតជាមួយនឹងទ្រព្យសម្បត្តិ៥៣,៥ពាន់លានដុល្លារ ក្លាយជាអ្នកមានជាងគេបំផុតលើពិភពលោក។ ក៏ប៉ុន្តែតើបេក្ខជនណាខ្លះជាអនាគតអ្នកមានជាងគេបំផុតលើពិភពលោក? ខាងក្រោមនេះជាសេដ្ឋីវ័យក្មេងបំផុតលើពិភពលោកទាំង ១០រូប ដកស្រង់ដោយទស្សនាវដ្ដី Forbes ៖

### ១-លោក MARK ZUCKERBERG ៖

មហាសេដ្ឋីវ័យក្មេងជនជាតិអាមេរិកអាយុ២៥ឆ្នាំរូបនេះមានប្រាក់ភាគហ៊ុនសកម្មចំនួន៤.០០០លានដុល្លារ។ជាអ្នកនៅលីវលោកMARK ZUCKERBERGរកស៊ីមានបានដោយសារអ៊ីនធើណេតគឺបង្កើតកម្មវិធី FACEBOOK ជាបណ្ដាញអ៊ីនធើណេតសង្គមមួយកាលពីឆ្នាំ២០០៤ ។

### ២-លោកចន អាណុល ៖

ជាមហាសេដ្ឋីវ័យក្មេងជនជាតិអាមេរិក មានអាយុ៣៦ឆ្នាំ មានប្រពន្ធរួចហើយ ដោយរូបគេមានប្រាក់៤.០០០លានដុល្លារ។គេរកស៊ីមានបានខាងពាណិជ្ជកម្មថាមពល។លោក ចន អាណុល ចូលរួមរកស៊ីក្នុងក្រុមហ៊ុន ENRONហើយគេបានបង្កើតក្រុមហ៊ុន CENTAURUS ENERGY ជាក្រុមហ៊ុនផ្ដល់មូលនិធិពិសេសខាងការធ្វើពាណិជ្ជកម្ម ផលិតផលថាមពលក្នុងឆ្នាំ២០០២ ក្រោយការរលំរលាយនៃក្រុមហ៊ុន ENRON ។

### ៣-នាងយ៉ាងហ្វីយ៉ាន ៖

ជាមហាសេដ្ឋីវ័យក្មេងចិន អាយុ២៨ឆ្នាំ មានស្វាមីរួចហើយ ដោយគេរកស៊ីមានបានខាងកម្មសិទ្ធិអចលនទ្រព្យ។ជាកូនស្រីរបស់លោកយ៉ាង ហ្គោក្វាង ដែលជាស្ថាបនិកមួយរូបនៃក្រុមហ៊ុន BIGUIYUAN ជាក្រុមហ៊ុនយក្សចិនមួយ រកស៊ីខាងផ្នែកកម្មសិទ្ធិអចលនទ្រព្យ នាងយ៉ាងហ្វីយ៉ាន មានភាគហ៊ុន៧០% ក្នុងក្រុមហ៊ុននេះ។ នាងមានទ្រព្យសម្បត្តិប្រមាណជា៣.៤០០លានដុល្លារ ។

### ៤-លោក ALBERT VON THURNUND TAXIS ៖

ជាសេដ្ឋីវ័យក្មេងជនជាតិអាល្លឺម៉ង់ អាយុ២៦ឆ្នាំ នៅលីវ ហើយមានទ្រព្យសម្បត្តិ២.២០០លានដុល្លារ ។ គេទទួលបានមរតកពីគ្រួសារ។ គ្រួសាររបស់លោក ALBERT ជាអ្នករកស៊ីសំខាន់ខាងប៉ុស្តិ៍ប្រៃសណីយ៍អឺរ៉ុប កាលពីសតវត្សទី១៦ ហើយគ្រួសារនេះបង្កើតគំរូក្រុមសីលធម៌ប្រៃសណីយ៍ដំបូងគេ។ មានអាយុ១៨ឆ្នាំ ALBERT ជាអ្នកទទួលមរតកលើទ្រព្យសម្បត្តិទាំងនេះ ហើយបច្ចុប្បន្នគេរស់នៅក្នុងវិមាន SANKT EMMERAM។

### ៥-លោកហ្សាដ ហារីរី ៖

ជាមហាសេដ្ឋីវ័យក្មេងជនជាតិលីបង់ អាយុ២៩ឆ្នាំ នៅលីវ ហើយមានទ្រព្យសម្បត្តិ...... (**តទៅទំព័រទី២៧**)

(តមកពីទំព័រទី២៦) ១.៤០០លានដុល្លារ។ គេរកស៊ីខាងសំណង់ និងវិនិយោគ។ ជាកូនពៅរបស់អតីតនាយករដ្ឋមន្ត្រីលីបង់ លោករ៉ាហ្វិក ហារីរី ដែលត្រូវគេធ្វើឃាត, លោកហ្វាដ ហារីរី ពេលនេះគ្រប់គ្រងក្រុមហ៊ុនដែលឪពុករបស់លោកបង្កើតឡើង។ ការវិនិយោគទាក់ទិនដល់ផ្នែកហិរញ្ញវត្ថុសំណង់ ប្រេងកាត ទូរគមនាគមន៍ និងកម្មសិទ្ធិអចលនទ្រព្យ។ល។

### ៦-លោកអៃមីនហារីរីះ

លោកអៃមីន ហារីរី យកសញ្ជាតិអារ៉ាប៊ី សាអ៊ូឌីត អាយុ៣១ឆ្នាំ មានទ្រព្យសម្បត្តិ១.៤០០លានដុល្លារ ។ លោករៀបការរួចហើយ និងរកស៊ីមានបានដោយសារសំណង់ និងវិនិយោគ។ លោកជាបងប្រុសរបស់លោកហ្វាដ ហារីរី ។ បងប្អូនហារីរី ទទួលមរតកយ៉ាងច្រើនពីឪពុករបស់គេ លោករ៉ាហ្វិក ហារីរី ។

### ៧-លោកយ៉ូស៊ីកាហ្សូតាណាកាះ

ជាជនជាតិជប៉ុន អាយុ៣៣ឆ្នាំ មានទ្រព្យសម្បត្តិ១.៤០០លានដុល្លារ ។ គេមិនដឹងថា តើលោករៀបការរួចហើយ ឬយ៉ាងណាទេ។ លោករកស៊ីមានបានដោយសារអ៊ីនធើរណេត ។ ដូចលោក ZUCKERBERG ដែរ លោកតាណាកា រកស៊ីកាក់កបដោយសារបណ្តាញអ៊ីនធើរណេតសង្គម គឺបណ្តាញ GREE ។

### ៨-លោកកូស្ទីយ៉ានទីនហ្ស៊ីវ៉ាហ្គោះ

ជាមហាសេដ្ឋីអាយុ៣៦ឆ្នាំ ជនជាតិអ៊ុយក្រែន ដោយមានទ្រព្យសម្បត្តិចំនួន១.២០០លានដុល្លារ។ លោករៀបការរួចហើយ និងរកស៊ីខាងផ្នែកធនាគារ និងរ៉ែ ។ លោកកូស្ទី យ៉ានទីន ហ្ស៊ីវ៉ាហ្គោ ជាម្ចាស់ភាគហ៊ុនសំខាន់របស់ក្រុមហ៊ុនរ៉ែ FERREXPO និងធនាគារ ហិរញ្ញវត្ថុ និងឥណទាន ។

### ៩-លោកលីហ្សាវហ្វីះ

ជាមហាសេដ្ឋីចិន អាយុ២៨ឆ្នាំ មានទ្រព្យសម្បត្តិ១.០០០លានដុល្លារ ។ គេពុំទាន់ដឹងថា គេរៀបការហើយ ឬនៅនោះទេ។ គេរកស៊ីមានបានដោយសារមរតកពីឪពុក។ ក្រោយការធ្វើឃាតឪពុករបស់គេកាលពីឆ្នាំ២០០៣ លោកលីហ្សាវហ្វី ក្លាយជាប្រធានក្រុមហ៊ុន SHANXI HAIXIN IRON AND STEEL GROUP ជាក្រុមហ៊ុនផលិតដែកថែបឯកជនធំជាងគេរបស់ចិន ។

### ១០-លោកសាហ៊ីដបាល់វ៉ាះ

ជាមហាសេដ្ឋីជនជាតិឥណ្ឌា អាយុ៣៦ឆ្នាំ មានទ្រព្យសម្បត្តិ១.០០០លានដុល្លារ និងមានប្រពន្ធរួចហើយ។ លោករកស៊ីខាងអចលនទ្រព្យ ។ លោកសាហ៊ីដ បាល់វ៉ា ជាដៃគូរបស់ក្រុមហ៊ុន DB REALTY ជាក្រុមហ៊ុនអចលនទ្រព្យធំជាងគេរបស់ឥណ្ឌា គ្រប់គ្រងជាពិសេសនូវសណ្ឋាគារ PARK HYATT MUMBAI HOTEL ។

*ឯកសារស្រាវជ្រាវ*

---

(តមកពីទំព័រទី២៥) ព្យាបាលការហូរឈាមជាដើម។ សូមប្រើឫស 15-30 ក្រាមដាំទឹក200 មីល្លីលីត្រ យក50 មីល្លីលីត្រ(ទឹកបីយកទឹកមួយ) ផឹកនៅរៀងរាល់ល្ងាចពី5-7ថ្ងៃនឹងជាសះស្បើយមិនខាន។

ក្រៅពីនេះផ្កាឈើនៅព្យាបាលជំងឺជាច្រើនទៀត៕

*ឯកសារស្រាវជ្រាវ*



លោកសេនាប្រមុខ **លន់ នល់** សម័យសាធារណរដ្ឋ

**(តមកពីទំព័រទី២១)** បាយបណ្ឌិតពៀងម៉េដ អាប់ឌុល ហ្គាហ្វា បានរំឭកអំពីហេតុការណ៍ខ្លះថា លោក លន់ នល់គ្រាន់តែស្នើឲ្យទ័ពព្រៃកុម្មុនិស្តវៀតកុង វៀតណាមខាងជើង ចេញឲ្យផុតពីដីខ្មែរមុនព្រឹកថ្ងៃ១៥មីនា ១៩៧០។

នៅថ្ងៃ១៣ មីនា ១៩៧០ ប្រធានាធិបតីសូវៀត Nikolai Podgorny ទូលសម្តេចព្រះ នរោត្តម សីហនុ ឲ្យយាងចូលកម្ពុជាវិញជាបន្ទាន់។ ថ្ងៃ១៥ មីនា ក្រសួងការបរទេសចិនស្នើឲ្យបារាំងត្រៀមយន្តហោះ Air France មួយគ្រឿង ដើម្បីដឹកព្រះអង្គពីក្រុងមូស្គូ តែព្រះអង្គនៅតែមិនព្រម។

មកទល់ពេលនេះ កូនខ្មែរជំនាន់ក្រោយដែលកើតមិនទាន់ហេតុការណ៍នាសម័យនោះ ក៏បានស្រាវជ្រាវរកការពិតអំពីព្រឹត្តិការណ៍នាពេលនោះដែរ។

លោក សួន សេរីរដ្ឋា នាយបេសកកម្មនៃគណៈកម្មាធិការប្រព្រឹត្តិកម្មខ្មែរដើម្បីយុត្តិធម៌ និងសមធម៌ នៅសហរដ្ឋអាមេរិក ឲ្យដឹងថា ខ្មែរនៅរដ្ឋកាលីហ្វ័រនីញ៉ា នឹងនាំគ្នាប្រារព្ធខួបទី៤០នេះ ដោយសារ ៖ *«យើងយល់និងឯកភាពទាំង អស់គ្នាថា ថ្ងៃ១៨ មីនា ឆ្នាំ១៩៧០នេះ គឺថ្ងៃសេរីភាពរបស់ខ្មែរ។ ថ្ងៃ១៨ មីនា ឆ្នាំ១៩៧០នេះហើយ ដែលធ្វើឲ្យខ្មែរមានការរួបរួមគ្នាប្រឆាំងនឹង ការឈ្លានពានរបស់យួនវៀតកុង។ ខ្មែរនៅក្នុងប្រទេសមានការឈឺចាប់ចំពោះការឈ្លានពាន គឺយើងទទួលស្គាល់ ហើយយើងឲ្យតម្លៃថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ គឺជាថ្ងៃកំណើតសេរីភាពរបស់ខ្មែរ សិទ្ធិសេរីភាព សម្រេចជោគវាសនាជាតិដោយខ្លួនឯង»*។

ប្រភព RFA

---

**(តមកពីទំព័រទី២៣)** តិចនិងអតីតយុទ្ធជន។ ការចំណាយលើប្រព័ន្ធសុខភាពទាំងពីរ តំណាងឲ្យ ៤% នៃផលិតផលសរុបក្នុងស្រុក។ ចាប់ពីពេលនេះ ដល់ឆ្នាំ ២០៥០ ការចំណាយលើប្រព័ន្ធសុខាភិបាលទាំងពីរ នឹងអាចកើនដល់ ១២%។ ចំពោះពលរដ្ឋអាមេរិកាំងប្រមាណជា ៦៤% ផ្សេងទៀត ពួកគេបានទិញសេវាធានាសុខភាព ពីក្រុមហ៊ុនឯកជន ក្នុងនោះមានភាគច្រើន ទិញតាមរយៈក្រុមហ៊ុន ដែលខ្លួនធ្វើការ ព្រោះថាមានក្រុមហ៊ុនខ្លះជួយចេញសោហ៊ុយឲ្យបុគ្គលិករបស់ខ្លួន ពី ៧០% ទៅ ៨០%។ មួយវិញទៀត ក្រុមហ៊ុនណាដែលជួយបង់ថ្លៃសេវាធានាសុខភាពដល់បុគ្គលិករបស់ខ្លួននឹងទទួលបានការកាត់បន្ថយសារពើពន្ធពីរដ្ឋ។

- **ជាជោគជ័យរបស់ពលរដ្ឋអាមេរិកាំង**

ប្រកបដោយទឹកមុខញញឹម លោក Barack Obama បានចាត់ទុកថា នេះមិនមែនជាជោគជ័យរបស់លោក ឬមួយរបស់គណបក្សលោកទេ តែជាជោគជ័យរបស់ពលរដ្ឋអាមេរិកាំងទាំងមូល។ អាចថា ជាជោគជ័យ ជាប្រវត្តិសាស្ត្រសម្រាប់សហរដ្ឋអាមេរិកផង ព្រោះថាមុនលោកប្រធានាធិបតី Barack Obama មានប្រធានាធិបតីពីររូប គឺលោក Roosevelt និងលោក Clinton ដែលបានព្យាយាមមិនបានសម្រេច ក្នុងការអនុម័តច្បាប់ស្តីពីប្រព័ន្ធសុខាភិបាលសម្រាប់ពលរដ្ឋអាមេរិកាំងទូទៅ។ ដូច្នេះ វាជារឿងមួយធម្មតាទេ ដែលលោក Obama កំពុងមានមោទនភាពរកអ្វីប្រៀបផ្ទឹមពុំបាន។

ដូច្នេះចង់ ឬមិនចង់ ជោគជ័យនេះ គឺជាខ្យល់ Oxygène នយោបាយមួយសម្រាប់លោក Obama នៅប៉ុន្មានខែ មុនការបោះឆ្នោតសភាពាក់កណ្តាលអាណត្តិ នៅខែវិច្ឆិកា ឆ្នាំ ២០១០៕

(តមកពីទំព័រទី២២) Luxembourg, Hollande និង Italie សុខចិត្តបង្កើតសហគមន៍ធ្យូងថ្មនិងដែកថែបអឺរ៉ុប La Communauté Européenne du Charbon et de l'Acier ហៅកាត់ថាCECA។

តាមរយៈ សហគមន៍CECA នេះ អឺរ៉ុបរួមចាប់បដិសន្ធិកើតចេញជារូបរាងឡើង នៅតូចកូនង៉ែតមែនពិត តែនឹងរីកធំធាត់ម្តងបន្តិចៗ ចាប់ពីដើមទសវត្សរ៍ទី៥០ទៅ។នៅក្នុងសម័យទសវត្សរ៍ទី៥០ ទ្វីបអឺរ៉ុបជាទីកន្លែងដែលសង្គ្រាមត្រជាក់រវាង Blocខាងកើតកុម្មុយនីស្ត និងBlocខាងលិចសេរី បង្កឲ្យមានភាពតានតឹងខ្លាំងជាងគេ។នៅក្នុងកាលៈទេសៈបែបនេះ ប្រទេសបារាំងមានគំនិតស្នើឲ្យបង្កើតកងទ័ពអឺរ៉ុបរួមមួយ រវាងបណ្តាប្រទេសសមាជិកទាំង៦។ គំនិតនេះលេចចេញជារូបរាងឡើងតាមរយៈ សន្ធិសញ្ញាទីក្រុងប៉ារីសឆ្នាំ១៩៥២ តែរលត់សាបសូន្យទៅវិញ នៅឆ្នាំ១៩៥៤។ ពីព្រោះ កាលនោះ រដ្ឋសភាបារាំង ដែលខ្លាចប្រទេសបារាំងបាត់បង់អធិបតេយ្យរបស់ខ្លួនមិនព្រមឲ្យសច្ចាប័នទៅលើសន្ធិសញ្ញានេះទេ ខុសផ្ទុយពីរដ្ឋសភាBelgique អាល្លឺម៉ង់ខាងលិច Hollande Luxembourg និងItalie។

សព្វថ្ងៃនេះ៦០ឆ្នាំក្រោយមកក្រុមប្រវត្តិវិទូនៅតែបន្តអះអាងថា បើសិនជារដ្ឋសភាបារាំង មិនច្រានចោលសន្ធិសញ្ញាបង្កើតកងទ័ពអឺរ៉ុបរួមនៅឆ្នាំ១៩៥៤នោះទេ ប្រហែលជាមានសហរដ្ឋអឺរ៉ុបមួយរួចស្រេចបាត់ទៅហើយនៅថ្ងៃនេះ។ នៅត្រង់នេះគេគួរបើករង់ក្រចកពិនិត្យមើលឥរិយាបថរបស់ប្រទេសបារាំងបន្តិចសិន។ ពីព្រោះនៅក្នុងអភិក្រមនៃការកសាងអឺរ៉ុបម្តងជាពីរដងបារាំងអស់ពីក្លាហានក្លាយជាកំសាកអស់ពីជម្រុញឲ្យទៅមុខ ក្លាយជាអ្នកយកជើងរាទឹក។ ជាក់ស្តែងជាងគេ គឺនៅឆ្នាំ២០០៥ ជាថ្មីម្តងទៀត ប្រទេសបារាំងច្រានចោលរដ្ឋធម្មនុញ្ញអឺរ៉ុប ដែលខ្លួនជាអ្នកផ្តួចផ្តើមជម្រុញឲ្យតុបតែងឡើង។យ៉ាងណាក៏ដោយ នៅក្នុងទសវត្សរ៍ទី៥០ ប្រទេសសមាជិកទាំង៦នៃសហគមន៍ធ្យូងថ្ម និងដែកថែបអឺរ៉ុប បន្តជម្រុញឲ្យទៅមុខកាន់តែលឿន គំនិតដែលថាត្រូវតែដើរទៅឲ្យដល់គោលដៅអឺរ៉ុបនយោបាយ។ នៅក្នុងន័យនេះ នៅឆ្នាំ១៩៥៧ បណ្តាប្រទេសអឺរ៉ុបទាំង៦ មូលមតិគ្នា បង្កើតសហគមន៍សេដ្ឋកិច្ចអឺរ៉ុប La Communauté Economique Européenne ហៅកាត់ថា CEE តាមរយៈសន្ធិសញ្ញាទីក្រុងRome។ គោលដៅនៃសន្ធិសញ្ញានេះ គឺបង្កើតឲ្យមានទីផ្សាររួមមួយ និង អនុញ្ញាតឲ្យមានដោយសេរីចរាចរមនុស្ស ចរាចរផលិតផល និងចរាចរមូលធន នៅក្នុងព្រំដែននៃបណ្តាប្រទេសសមាជិកទាំង៦ របស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប CEE ។ ដោយសារតែសហគមន៍សេដ្ឋកិច្ចអឺរ៉ុប ការផ្លាស់ប្តូរពាណិជ្ជកម្មរវាងបណ្តាប្រទេសសមាជិកទាំង៦ កើនឡើងខ្លាំង កើនមួយជាប្រាំ ក្នុងចន្លោះឆ្នាំ១៩៥៧ និងឆ្នាំ១៩៧០។រីឯផលិតផលដែលសហគមន៍លក់ចេញទៅក្រៅវិញក៏កើនឡើងបានមួយជាបី។និយាយរួមសហគមន៍សេដ្ឋកិច្ចអឺរ៉ុប គឺជាជ័យជំនះសេដ្ឋកិច្ចមួយប្រកែកមិនបាន៕ *ប្រភព RFI*

---


# *ប្រេងខ្យល់ប្រទាលខ្មែរបុរាណ*

**វិធីប្រើ៖** លាបនៅពេលដែលចុកដៃជើង, ស្ពឹកស្រពន់, ចុកចង្កេះ, ថ្លោះគ្រិច, ឈឺក្បាល, វិលមុខ, ពុលឡានពុលកាណូត, ពុលយន្តហោះ, ចុកពោះ, ធ្លល់ពោះ, ហើមពោះ, ណែនពោះ, តឹងច្រមុះ, ផ្តាសាយ, មូសខាំ, ក្អែកខាំស្រាំងទិច, ឱម៉ាលទិច, ឡើងកន្ទួល, រមាស់ផ្សេងៗ.......។ **បញ្ជាក់៖** *ហាមយកប្រេងខ្យល់នេះទៅលាបភ្នែក។*

**លោក អ្នក ចង់បានប្រេងខ្យល់ប្រទាលខ្មែរបុរាណ សូមទំនាក់ទំនងទូរស័ព្ទលេខ៖ (408) 923-2166**

# ប្រសិទ្ធិពរឆ្នាំថ្មី

ដំណើរជីវិតសត្វលោកា
សតិបញ្ញាស្មារតីថ្លៃ
វិញ្ញាណឧត្តមតែងខ្វល់ខ្វាយ
ជ្រើសរើសឧបាយផ្លូវសុចរិត ។
ទំនៀមទម្លាប់នៃជាតិសាសន៍
ខ្មែរគ្រប់ឋានៈសប្បាយចិត្ត
សហមេត្រីថ្លៃពិសិដ្ឋ
សាមគ្គីគំនិតច្នៃការងារ ។
ប្រពៃណីវប្បធម៌ខ្មែរបុរាណ
រុងរឿងថ្កើងថ្កានល្បីនាមា
សុវណ្ណភូមិទឹកដីដែនកម្ពុជា
ផ្តល់ភាពរមនាសុខក្សេមក្សាន្ត ។
សួស្តី ! ឆ្នាំចាស់ ! ផ្លាស់ឆ្នាំថ្មី
ប្រជាប្រុសស្រីគ្រប់មជ្ឈដ្ឋាន
ព្យាយាមតស៊ូចិត្តក្លាហាន
ការពារមូលដ្ឋានរដ្ឋបូរី ។
ឆ្នាំផ្លូវឯកស័កថ្នាក់ថ្នមមិត្ត
លួងលោមជីវិតរីតនិស្ស័យ
ជញ្ជីងយុត្តិធម៌ទ្រលោកីយ៍
គ្រប់គ្រងផែនដីផ្ទៃមេត្តា ។
ព្រះសង្ឃបណ្ឌិតនិស្សិតកម្ពុជា
ទឹកចិត្តរួមគ្នាចងសហការ
ឆ្នាំចាស់ឆ្លងផុតផ្តិតវាសនា
ឆ្នាំថ្មីសច្ចាស្តាររឿងពិត ។
សង្គមតូចធំខ្មែរផ្តុំទស្សនៈ
ខ្មែរគ្រប់វណ្ណៈផ្លាស់ចរិត
ស្រឡាញ់មាតុភូមិដែនពិសិដ្ឋ
ចូលរួមគំនិតគិតគ្រប់គ្នា ។
ខ្មែរជាតិនិយមជុំបញ្ញវ័ន្ត
ខ្មែរច្រើនពេកពន់រួមសាមគ្គា
បង្កើតសមាគម-វត្តនានា
ទិសដៅការពារស្វ័យវប្បធម៌ ។
ឆ្នាំថ្មីនិងចាស់ ខ្មែរ-ខ្មែរក្រោម
ឆន្ទៈដល់ព្រមដោយគុណធម៌
ស្វាគមន៍ **ឆ្នាំខាល** ថ្លៃបវរ
ឆ្នាំថ្មីបន្ត ! ចិត្តមោទនៈ ។
ថ្ងៃជោគសិរីចារប្រវត្តិ
សារតាកំណត់ខ្មែរក្មេងចាស់
ជាតិខ្មែរពូតផ្តុំជុំម្ចាស់ផ្ទះ
ការពារពូជសាសន៍សីមាឋាន។
ឆ្នាំខាលទោស័កជ័យបន្ត
ឆ្នាំថ្មីបវរពាសីថ្កាន
**មណ្ឌលទេវី** ចិត្តកល្យាណ
ទ្រទ្រង់អង្គប្រាណញាតិប្រុសស្រី។
ជាតិខ្មែរ-ខ្មែរក្រោមរួមគំនិត
កសាងជីវិតគិតតម្លៃ
**មត៌កខ្មែរ** ផ្សាយចិត្តភក្តី
សូមជូនសិរីដល់ជាតិខ្មែរ... ។

ដោយ ភិក្ខុ សឹង យ៉ឹង រតនា

# រាសីប្រចាំខែមេសា

**១.ឆ្នាំជូត:** រាសីខែនេះល្អមធ្យម។ ថ្ងៃនេះលោកអ្នកនឹងកើតការខ្វាយខ្វល់ផ្លូវចិត្តច្រើន។ ចំណែកកិច្ចការរកទទួលទានមិនមានប្រែប្រួលឡើយ។ រីឯការរស់នៅវិញ លោកអ្នកមានភាពផុយស្រួយ គួរប្រយ័ត្នប្រយែងឲ្យបានខ្លាំងក្លា។

**២.ឆ្នាំឆ្លូវ** រាសីខែនេះស្រុតចុះ។ បើចង់សំរុះសំរួល ឬណាត់ជួបអ្នកណាម្នាក់នោះ មិនបានជួបដូចបំណង។ ការប្រកបរបរជួញដូរមានភាពខ្សត់ខ្សោយ។ ការធ្វើដំណើរផ្លូវឆ្ងាយត្រូវប្រុងប្រយ័ត្ន។ជីវិតរស់នៅមានការមិនចុះសម្រុងនឹងគ្នាទេ។

**៣.ឆ្នាំខាល** រាសីខែនេះខ្ពស់ត្រដែត។ ការប្រកបរបររកស៊ីផ្សេង ៗទទួលបានជោគជ័យ។ ការធ្វើដំណើរកំសាន្តជួបតែសេចក្តីសុខក្សេមក្សាន្ត។ រីឯជីវិតរស់នៅក្នុងសង្គមគ្រួសារវិញ មានភាពរុះរាយនិងយល់ចិត្តគ្នា ហើយជាឱកាសល្អសំរាប់លោកអ្នកមានបំណងចង់រៀបចំគ្រួសារផងដែរ។

**៤.ឆ្នាំថោះ** រាសីខែនេះល្អមធ្យម។ រយៈពេលនេះ កិច្ចការងារណាដែលបំពេញខ្លួនឯងបានគួរខិតខំឲ្យអស់ពីកំលាំងកាយចិត្តនឹងទទួលបានផលល្អ។ ដំណើរចាកចេញក្រៅផ្ទះត្រូវប្រកាន់ចិត្តឲ្យនឹងធឹងមានគេព្យាបាទ តែពុំបានសំរេចទេ។ ចំពោះការរស់នៅមានភាពផ្អែមល្ហែមនិងជូរចត់រត់រកគ្នា។

**៥.ឆ្នាំរោង** ដួងរាសីខែនេះល្អបង្គួរ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរមានភាពគាប់ប្រសើរ អាចប្រមូលបានផលច្រើន។ ការធ្វើដំណើរជិតឆ្ងាយមានភាពសុខសាន្ត។ សេចក្តីស្នេហាវិញមានសភាពស្រស់ស្រាយល្អប្រពៃ ប្រៀបដូចត្រីនៅក្នុងទឹកនារដូវវស្សា។

**៦.ឆ្នាំម្សាញ់** រាសីខែនេះល្អជាមធ្យម។ចំពោះការប្រកបរបរជួញដូរប្រាក់ចំណូលរកបានដោយតានតឹងណាស់។ បើការចេញដំណើរផ្លូវឆ្ងាយត្រូវប្រុងប្រយ័ត្នបន្តិច ក្រែងជួបគ្រោះថ្នាក់។ រីឯការរស់នៅក្នុងសង្គមគ្រួសារវិញមានការអធ្យាស្រ័យគ្នាទៅវិញទៅមកបានច្រើន។

**៧.ឆ្នាំមមី** រាសីខែនេះស្រុតចុះ។លោកអ្នកប្រកបការងារមានលំនឹងល្អ បើចង់បោះទុនរកស៊ីត្រូវប្រយ័ត្នបន្តិច ព្រោះផលតបស្នងមកវិញតិចតួចណាស់។បញ្ហាសង្គមគ្រួសារវិញនោះមានដំណើរថយក្រោយនិងចាប់កំហុសគ្នាកាន់តែច្រើន។

**៨.ឆ្នាំមមែ** រាសីខែនេះល្អបង្គួរ។ ការជួញដូរផ្សេងៗនឹងគាប់ប្រសើរគួរសម ដូច្នេះលោកអ្នកត្រូវតែខិតខំប្រឹងប្រែង។ ចំពោះការធ្វើដំណើរវិញ មិនមានអ្វីមករារាំងបានទេ ។ចំណែកការរស់នៅមានចំណងរឹងមាំល្អ ចេះអត់ឱនឱ្យគ្នា។

**៩.ឆ្នាំវក** ដួងរាសីខែនេះល្អមធ្យម។ ចំពោះលោកអ្នកប្រកបរបររកស៊ីទទួលបានផលល្អ។ ការធ្វើដំណើរផ្លូវឆ្ងាយពុំសូវមានសុវត្ថិភាពទេ ប្រយ័ត្នឧប្បត្តិហេតុកើតឡើង។ ចំណងអាពាហ៍ពិពាហ៍វិញនោះ មានការប្រែប្រួលមិនទៀងទាត់ទេព្រោះការមិនទុកចិត្តគ្នា។

**១០.ឆ្នាំរកា** រាសីខែនេះល្អមធ្យម។ ដំណើរជីវិតប្រកបទៅមុខមិនមានការផ្លាស់ប្តូរនិងទទួលជោគជ័យជានិច្ច។ ចំពោះការប្រកបរបររកស៊ីជួញដូរនឹងបានផលគួរសម។ ចំពោះការរស់នៅមានដំណើរជឿនលឿនទៅមុខបង្គួរ។

**១១.ឆ្នាំច** រាសីខែនេះខ្ពស់ត្រដែត។ ការធ្វើដំណើរចាកចេញទៅក្រៅផ្ទះលោកអ្នកមានសុវត្ថិភាពល្អញាតិមិត្តរាប់អាន។ រីឯការរកទទួលទានវិញគឺបានផលច្រើន។ចំណែកការរស់នៅលោកអ្នកនឹងមានសុភមង្គលល្អណាស់ ក្នុងសង្គមគ្រួសារ។

**១២.ឆ្នាំកុរ** រាសីខែនេះល្អបង្គួរ។ សំរាប់លោកអ្នកប្រកបរបររកស៊ីទទួលបានផលចំណេញគួរសម។ ការធ្វើដំណើរជិតឆ្ងាយគ្មានអ្វីជាឧបសគ្គទេតែត្រូវប្រយ័ត្នបន្តិច ។ចំណែកក្នុងរង្វង់គ្រួសារមានភាពរីកចំរើន ចេះយល់យោគគ្នាច្រើន និងមានទឹកចិត្តអធ្យាស្រ័យខ្ពស់។

# ហាងមាសមេគង្គ

# 湄江 MEKONG 珠寶
## JEWELRY



- **មានលក់មាសនិងពេជ្រគ្រប់ប្រភេទ**
- មានលក់គុជនិងត្បូងពេជ្រជាច្រើនសម្រាប់ធ្វើជាខ្សែក, ខ្សែដៃ, ក្រវិលនិងចិញ្ចៀន។ល។
- ទទួលរចនាគ្រឿងអលង្ការគ្រប់មុខគ្រប់ម៉ូដតាមការនិយមចូលចិត្តបែបបុរាណឬសម័យ។
- ទទួលជួសជុលគ្រឿងអលង្ការភ្លាមៗ !!!

សូមស្វាគមន៏អតិថិជនគ្រប់ទិសទី !!!

- **All Kinds of Diamonds & golds**
- COUNTLESS OF STYLES AVAILABLE FOR RINGS, NECKLACE, BRACELETS, ETC.
- WE ACCOMODATE ANY DESIGN THAT BEST SUITS YOUR INTERESTS.
- WE ARE MORE THAN HAPPY TO FIX OR REDESIGN YOUR PREOWNED JEWELRY.
- A VISIT TO OUR STORE WILL GUARANTEE YOUR SATISFACTIONS.

ADDRESS:
1954 ABORN ROAD
SAN JOSE, CA 95121

KIM
TEL: (408) 238-3377
FAX: (408) 238-2601